សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អាហារភោគពូកិច្ចតាមផ្លូវតុលាការ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក ឡេង រតនា**

**កញ្ញា ប៉ុក រ៉ានីតា**

សាស្ត្រាចារ្យណែនាំ

**លោក គង់ សុភ័ក្ត្រ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# **សេចក្តីថ្លែងអំណរគុណ**

ជាបឋមខ្ញុំបាទ **ឡេង រតនា** និង នាងខ្ញុំ **ប៉ុក រ៉ានីតា** ដែលមានលេខកូដថ្នាក់ L4A1 ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៧-២០២១ សូមថ្លែងអំណរគុណ និងសម្តែងនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ៖

**លោកឪពុក អ្នកម្តាយ** ដ៏មានគុណដែលពុំអាចកាត់ថ្លៃបាន ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូន ដោយចិត្តសណ្តោសប្រណី អប់រំប្រៀនប្រដៅ ប្រកបដោយព្រហ្មវិហារធម៌ គុណធម៌ សប្បុរសធម៌ ហើយថែមទាំងបានផ្គត់ផ្គង់ ដល់ការសិក្សាតាំងពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់ឧត្តមសិក្សា។ លើសពីនេះទៅទៀត លោកទាំងពីរ បានជួយឧបត្ថម្ភគាំទ្រផ្នែកថវិកា លើកទឹកចិត្ត ជម្រុញស្មារតី ដើម្បីជាមធ្យោបាយឲ្យយើងខ្ញុំទទួលបាននូវចំណេះដឹង រហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

យើងខ្ញុំទាំងពីរនាក់ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លុយ ចណ្ណា និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក លោកស្រី អ្នកនាងកញ្ញា ជាសាស្ត្រាចារ្យ បុគ្គលិកការិយាល័យសិក្សា ការិយាល័យស្រាវជ្រាវ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែង គ្រប់គ្រង ដឹកនាំ បង្ហាត់បង្រៀនផ្តល់នូវចំណេះដឹង បទពិសោធន៍ល្អៗ និងអនុសាសន៍ល្អៗ ដោយពុំខ្លាចនឿយហត់ ដល់យើងខ្ញុំដែលជានិស្សិតទាំងអស់គ្នា។ ដើម្បីឲ្យយើងខ្ញុំដែលជានិស្សិត ទុកធ្វើជាមូលដ្ឋានចំណេះដឹងដ៏រឹងមាំក្នុងការប្រកបវិជ្ជាជីវៈឲ្យកាន់តែប្រសើរ ដែលប្រកបដោយគុណភាព និងចូលរួមពង្រឹង វិស័យច្បាប់នៅកម្ពុជាឲ្យកាន់តែមានភាពរីកចម្រើនប្រកបទៅដោយចីរភាព។

នាឱកាសដ៏ពិសេសនេះផងដែរ យើងខ្ញុំទាំងពីរ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះលោកសាស្ត្រាចារ្យ **គង់ សុភ័ក្រ** ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ ទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការជួយសម្រួល កែតម្រូវ ជម្រុញលើកទឹកចិត្ត ថែមទាំងផ្តល់ចំណេះដឹង និងដំបូន្មានល្អៗក្នុងការណែនាំយើងខ្ញុំយ៉ាងយកចិត្តទុកដាក់បំផុត ដើម្បីចងក្រងសារណាបញ្ចប់ឆ្នាំសិក្សាមួយនេះ អោយមានប្រសិទ្ធិភាព គុណភាព និងប្រកបដោយជោគជ័យ។

ជាចុងបញ្ចប់ យើងខ្ញុំសូម សម្តែងសេចក្តីគោរព និងប្រសិទ្ធពរជ័យជូនចំពោះ លោកអ្នកដែលមានគុណ បងប្អូន ញាតិមិត្ត ក៏ដូចជា ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងបុគ្គលិកគ្រប់ជាន់ថ្នាក់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមឲ្យជួបតែពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិរន្ត និងជោគជ័យគ្រប់ភារកិច្ច។

# **អារម្ភកថា**

ក្រោយពីយើងខ្ញុំទាំងពីរ បានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ៤ឆ្នាំ យើងខ្ញុំទាំងពីរបានក្រេបយកចំណេះដឹងថ្មីៗដែលពុំធ្លាប់បានដឹងពីមុនមក ព្រមទាំងទទួលបានចំណេះដឹង និងបទពិសោធន៍យ៉ាងច្រើននៅក្នុងវិស័យច្បាប់មួយនេះផងដែរ។ លើសពីនេះទៅទៀត ដើម្បីឆ្លើយតបដល់ការខិតខំប្រឹងប្រែង របស់លោក លោកស្រីសាស្ត្រាចារ្យ នៅក្នុងការបង្រៀន ជម្រុញលើកទឹកចិត្ត និងផ្តល់នូវឯកសារដ៏សម្បូរបែប សម្រាប់ជាជំនួយដល់និស្សិតគ្រប់រូប និងដើម្បីជាការវាយតម្លៃ វាស់ស្ទង់សមត្ថភាពចំណេះដឹងរបស់យើងខ្ញុំ ដែលបានចំណាយពេលសិក្សាស្វែងយល់ រយៈពេល ៤ឆ្នាំ កន្លងមកនេះ យើងខ្ញុំសូមលើកយកប្រធានបទមួយស្តីពី **អាហារកាតព្វកិច្ចតាមផ្លូវតុលាការ** មកធ្វើជាការសិក្សាស្រាវជ្រាវដើម្បីធ្វើជាសារណាបញ្ចប់ការសិក្សា។

មូលហេតុដែលជម្រុញឲ្យយើងខ្ញុំសម្រេចចិត្ត ជ្រើសរើសយកប្រធានបទនេះមកស្រាវជ្រាវ និងធ្វើជាសារណា គឺចង់ពន្យល់បង្ហាញ ដល់មិត្តនិស្សិត និងមិត្តអ្នកអានដែលចង់ស្វែងយល់បន្ថែម ថាតើអ្វីទៅជាអាហារកាតព្វកិច្ច ហើយអាហារកាតព្វកិច្ចមានសារៈសំខាន់កម្រិតណាដល់អ្នកដែលមានសិទ្ធិទទួល។ លើសពីនេះទៅទៀត តើអាហារកាតព្វកិច្ចតាមផ្លូវតុលាការ អាចត្រូវធ្វើឡើងបានដោយរបៀបណា។ ជាការពិតណាស់តាមរយៈស្នាដៃសារណា លើប្រធានបទមួយនេះ យើងខ្ញុំទាំងពីរសង្ឃឹមយ៉ាងមុតមាំថា អត្ថបទសារណាមួយនេះពិតជាអាចចូលរួមចំណែក ក្នុងការបណ្តុះបណ្តាលចំណេះដឹងបន្ថែម នៅក្នុងវិស័យច្បាប់ឲ្យកាន់តែមានភាពរីកចម្រើនបន្ថែមទៀត។ លើសពីនេះទៅទៀត ប្រធានបទមួយនេះក៏អាចចូលរួមចំណែកក្នុងការកសាងធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាពក្នុងការបំពេញវិជ្ជាជីវៈ ដែលជាកត្តាដ៏ចាំបាច់បំផុតសម្រាប់ការកសាងជាតិមាតុភូមិយើង ឲ្យមានការរីកចម្រើនលូតលាស់ លើគ្រប់វិស័យ និងមានការអភិវឌ្ឍជាដរាប។

សារណាមួយនេះ គឺជាស្នាដៃដែលយើងខ្ញុំទាំងពីរ បានខិតខំចំណាយពេលសិក្សាស្វែងយល់រាល់លិខិតបទដ្ឋានគតិយុត្ត និងឯកសារផ្សេងៗដែលពាក់ព័ន្ធ យ៉ាងយកចិត្តទុកដាក់បំផុត។ បើទោះបីជាអត្ថបទសារណាមួយនេះបានលេចជារូបរាងក៏ពិតមែន ក៏ប៉ុន្តែរាល់ចំណុចខ្វះខាត និងកំហុសខុសឆ្គងចំពោះអត្ថន័យ និងអក្ខរាវិរុទ្ធដោយអចេតនា ប្រាកដជាអាចមានជាក់ជាមិនខាន។ អាស្រ័យហេតុនេះហើយ យើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ និងរង់ចាំទទួលស្វាគមន៍រាល់មតិរិះគន់ក្នុងគោលបំណងស្ថាបនា និងកែលម្អពីសំណាក់លោកគ្រូ អ្នកគ្រូ និងមិត្តអ្នកអានទាំងអស់គ្នា ដើម្បីធ្វើអោយស្នាដៃនេះមានអត្ថន័យ និងខ្លឹមសារកាន់តែប្រសើរឡើង។ ជាចុងក្រោយយើងខ្ញុំ សូមថ្លែងអំណរគុណ និងសូមប្រសិទ្ធិពរជ័យដល់មិត្តៗអ្នកអាន សូមជួបប្រទះតែសំណាងល្អ សុខភាពល្អ និងប្រកបការងារអ្វីសម្រេចគ្រប់ភារកិច្ច។

# មាតិកា

**ទំព័រ**

## សេចក្តីផ្តើម


**១. លំនាំបញ្ហានៃការស្រាវជ្រាវ** ........................................ ១

**២. ចំណោទបញ្ហានៃការស្រាវជ្រាវ** ........................................ ១

**៣. គោលបំណងនៃកិច្ចការស្រាវជ្រាវ** ........................................ ១

**៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ** ........................................ ២

**៥. សារៈសំខាន់នៃការស្រាវជ្រាវ** ........................................ ២

**៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ** ........................................ ២


## ជំពូកទី១

## សញ្ញាណទូទៅនៃអាហារកាតព្វកិច្ច


**១.១ អាហារកាតព្វកិច្ច** ........................................ ៣

**១.១.១ និយមន័យនៃអាហារកាតព្វកិច្ច** ........................................ ៣

**១.១.២ ប្រភេទនៃអាហារកាតព្វកិច្ច** ........................................ ៣

ក. អាហារកាតព្វកិច្ចតាមផ្លូវច្បាប់ ........................................ ៣

ខ. អាហារកាតព្វកិច្ចតាមការព្រមព្រៀង ........................................ ៤

គ. អាហារកាតព្វកិច្ចតាមផ្លូវតុលាការ ........................................ ៤

ឃ. អាហារកាតព្វកិច្ចតាមទំនៀមទម្លាប់ ........................................ ៥

**១.១.៣ លក្ខខណ្ឌនៃការអនុវត្តការផ្តត់ផ្គង់អាហារកាតព្វកិច្ច** ........................................ ៥

**១.១.៤ លក្ខណៈនៃអាហារកាតព្វកិច្ច** ........................................ ៦

**១.២ ជនដែលពាក់ព័ន្ធក្នុងការទាមទារអាហារកាតព្វកិច្ច** ........................................ ៧

**១.២.១ បុគ្គលដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច** ........................................ ៧

ក. ញាតិដែលរស់នៅជាមួយគ្នា ........................................ ៨

ខ. ញាតិលោហិតខ្សែផ្ទាល់........................................ ៩

គ. បងប្អូនបង្កើត ........ ៩
ឃ. ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចតាមសេចក្តីសម្រេចរបស់តុលាការ ........ ១០
**១.២.២ បុគ្គលដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច** ........ ១១
ក. បុគ្គលខ្វះខាតផ្នែកជីវភាព ........ ១២
ខ. មានទំនាក់ទំនងញាតិ ជាមួយអ្នកមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ........ ១២
គ. អាចបង្ហាញឆន្ទៈ ឬទាមទារតាមផ្លូវតុលាការ ឬសុំរក្សាការពារដើម្បីទ្រទ្រង់ជីវភាពរស់នៅជាអប្បបរមា...... ១៣

## ជំពូកទី ២

## នីតិវិធីនៃការទាមទារអាហារកាតព្វកិច្ច

**២.១ ដំណាក់កាលនៃការដាក់ពាក្យសុំទាមទារអាហារកាតព្វកិច្ច** ........ ១៤
**២.១.១ នីតិវិធីនៃការដាក់ពាក្យសុំ** ........ ១៤
ក. ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ ........ ១៤
ខ. របៀបនៃការដាក់ពាក្យសុំ ........ ១៤
**២.១.២ ការបង់ប្រាក់ប្រដាប់ក្តី** ........ ១៥
ក. ពន្ធដាក់ពាក្យសុំ ........ ១៥
ខ. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ........ ១៥
**២.២ ដំណាក់កាលនៃការវិនិច្ឆ័យ និងសម្រេចសេចក្តី** ........ ១៧
**២.២.១ ការវិនិច្ឆ័យ** ........ ១៧
ក. ការស្រាវជ្រាវ និង ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ ........ ១៧
ខ. នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ........ ១៨
គ. មូលដ្ឋានគណនាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច ........ ១៩
**២.២.២ ការសម្រេចសេចក្តី** ........ ២១
ក. វិធីសម្រេចសេចក្តី ........ ២១
ខ. ការជូនដំណឹងអំពីដីកាសម្រេច ........ ២១
គ. ការចូលជាស្ថាពរ និងការបង្កើតអានុភាពនៃការសម្រេច ........ ២២

ឃ. អានុភាពនៃការអនុវត្តសេចក្តីសម្រេច ..................... ២៣
**២.៣ ដំណាក់កាលនៃការផ្តល់អាហារកាតព្វកិច្ច និងទណ្ឌកម្ម** ..................... ២៣
**២.៣.១ កម្រិតនៃការផ្តត់ផ្គង់អាហារកាតព្វកិច្ច** ..................... ២៣
ក. ការផ្គត់ផ្គង់ ការផ្លាស់ប្តូរ ឬការលុបចោល និងអនុប្បទានអាហារកាតព្វកិច្ច ..................... ២៣
ខ. ការបញ្ចប់ការផ្គត់ផ្គង់អាហារកាតព្វកិច្ច ..................... ២៥
**២.៣.២ ទណ្ឌកម្មនៃការមិនផ្គត់ផ្គង់អាហារកាតព្វកិច្ច** ..................... ២៥
ក. ការបង្ខំដោយអំណាចតុលាការឱ្យផ្គត់ផ្គង់កាតព្វកិច្ច ..................... ២៦
ខ. ការទទួលខុសត្រូវព្រហ្មទណ្ឌ ..................... ២៦
**សេចក្តីសន្និដ្ឋាន** ..................... ២៨
**អនុសាសន៍** ..................... ៣០
**ឯកសារយោង**
**បញ្ជីរាយនាមឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ជាទូទៅស្ថានភាពនៃការរស់នៅក្នុងសង្គមបច្ចុប្បន្ន មនុស្សគ្រប់រូបរមែងតែងតែមានជីវភាពរស់នៅមិនដូចគ្នានោះទេ ដូចជាកត្តា ស្ថានភាពរស់នៅ ស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាទិ៍។ យើងតែងតែសង្កេតឃើញថា បុគ្គលមួយចំនួនមានទ្រព្យសម្បត្តិស្តុកស្តម្ភ មួយចំនួនមានជីវភាពក្រីក្រ និងខ្លះទៀតពុំមានសមត្ថភាពក្នុងការចិញ្ចឹមជីវិតខ្លួនឯង រហូតក្លាយខ្លួនទៅជាទុគ៌តជនជាអាទិ៍។ បើយើងក្រឡេកមកមើលសង្គមខ្មែរ តែងតែប្រកាន់ខ្ជាប់នូវវប្បធម៌ ដែលឪពុកម្តាយមានកាតព្វកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូន ដោយផ្តល់នូវការអប់រំ កូនមានករណីយកិច្ចមើលថែទាំឪពុកម្តាយនៅពេលគាត់ចម្រើនវ័យចាស់ជរា និងបងប្អូនចេះជួយយកអាសារគ្នាទៅវិញទៅមក។

ដោយឡែកបើទោះបីជាសង្គមខ្មែរប្រកាន់ខ្ជាប់ នូវការចេះជួយគ្នារវាងញាតិក៏ពិតមែន ប៉ុន្តែយើងតែងតែសង្កេតឃើញមានស្ថានភាពមួយចំនួនដែលកើតមានឡើង ដូចជា ឪពុកម្តាយមិនចិញ្ចឹមកូន កូនមិនចិញ្ចឹមឪពុកម្តាយ បងប្អូនមិនជួយផ្គត់ផ្គង់គ្នាទៅវិញទៅមក។ ពោលគឺ មិនផ្តល់អាហារកាតព្វកិច្ចដល់ញាតិដែលខ្វះខាត ដែលជាស្ថានភាពមួយបង្កផលប៉ះពាល់ ផ្នែកសីលធម៌ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គម។

ដោយសារតែមើលឃើញពីបញ្ហាទាំងអស់នេះហើយ ទើបយើងខ្ញុំធ្វើការស្រាវជ្រាវលើ ប្រធានបទ **អាហារកាតព្វកិច្ចតាមផ្លូវតុលាការ**។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តាមរយៈការរៀបរាប់អំពីបញ្ហាដែលបានលើកឡើងខាងលើនេះ តើជនដែលខ្វះសមត្ថភាពក្នុងការចិញ្ចឹមជីវិតរបស់ខ្លួនឯង ឬ ត្រូវបានគេបោះបង់ចោលទាំងនោះ អាចធ្វើការទាមទារអាហារកាតព្វកិច្ចនេះបានដោយរបៀបណា? ហើយបុគ្គលណាខ្លះដែលត្រូវបានកំណត់ជាអ្នកទទួលបានអាហារកាតព្វកិច្ច និងបុគ្គលណាខ្លះដែលជាប់ករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច? លើសពីនេះទៅទៀត ប្រសិនបើអ្នកមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច មិនព្រមអនុវត្តតាមដីកាសម្រេច នោះតុលាការមានវិធានការយ៉ាងដូចម្តេចចំពោះជននោះ?

## ៣. គោលបំណងនៃកិច្ចការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវលើប្រធានបទនេះ មានគោលបំណងចូលរួមចំណែក ក្នុងការអនុវត្តច្បាប់ដែលទាក់ទងទៅនឹង ការទាមទារអាហារកាតព្វកិច្ចដែលកំណត់ដោយច្បាប់ពិសេស ដើម្បីផ្តល់នូវចំណេះដឹងបន្ថែមទាក់ទងនឹងប្រធានបទ នៃកិច្ចការស្រាវជ្រាវស្តីពី អាហារកាតព្វកិច្ចតាមផ្លូវតុលាការ។ ជាងនេះទៅទៀត កិច្ចការស្រាវជ្រាវលើប្រធានបទនេះ ក៏មានគោលបំណងបង្ហាញពីសិទ្ធិ និងនីតិវិធីនៃការទាមទារអាហារកាតព្វកិច្ច របស់ជនមានសិទ្ធិទទួលអាហារកាតព្វកិច្ច។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

មានមូលហេតុជាច្រើនក្នុងការទទួលបានអាហារកាតព្វកិច្ច ប៉ុន្តែដើម្បីឲ្យការស្រាវជ្រាវមួយប្រព្រឹត្តទៅបានល្អ និងអាចធ្វើការវិភាគគ្រប់ជ្រុងជ្រោយបាន វិសាលភាពនៃការស្រាវជ្រាវផ្តោតសំខាន់តែលើ **អាហារកាតព្វកិច្ចតាមផ្លូវតុលាការ** តែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

អ្វីដែលជាសារៈសំខាន់នៃការស្រាវជ្រាវលើប្រធានបទនេះ គឺចង់ឲ្យអ្នកសិក្សានៅគ្រប់មជ្ឈដ្ឋាន បានស្វែងយល់ឲ្យកាន់តែច្បាស់ អំពីអាហារកាតព្វកិច្ច ជនដែលត្រូវទទួលបានសិទ្ធិ អ្នកដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច កម្មវត្ថុនៃអាហារកាតព្វកិច្ច និងនីតិវិធីនៃការដាក់ពាក្យសុំទាមទារអាហារកាតព្វកិច្ច។ ជាងនេះទៅទៀត ប្រធានបទនេះ ក៏អាចក្លាយទៅជាឯកសារជំនួយដល់អ្នកសិក្សាជំនាន់ក្រោយក្នុងការស្វែងយល់បន្ថែម។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ក្នុងការស្រាវជ្រាវ យើងខ្ញុំបានធ្វើការសិក្សាដោយផ្អែកលើ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង បណ្តាលិខិតបទដ្ឋានគតិយុត្តផ្សេងៗ និងបណ្តាសៀវភៅសិក្សាផ្សេងទៀត សម្រាប់យកមកធ្វើជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវសម្រាប់ប្រធានបទមួយនេះ។

ដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់ទៅលើបញ្ហាខាងលើ នៅក្នុងសារណានេះ នឹងធ្វើការបែងចែកខ្លឹមសារជាពីរជំពូកសំខាន់ៗដូចជា សញ្ញាណទូទៅនៃអាហារកាតព្វកិច្ច (ជំពូកទី១) និង នីតិវិធីនៃការទាមទារអាហារកាតព្វកិច្ច (ជំពូកទី២)។

# ជំពូកទី១

# សញ្ញាណទូទៅនៃអាហារកាតព្វកិច្ច

## ១.១ អាហារកាតព្វកិច្ច

### ១.១.១ និយមន័យនៃអាហារកាតព្វកិច្ច

អាហារកាតព្វកិច្ច សំដៅទៅលើកិច្ចមួយដែលបុគ្គលម្នាក់ត្រូវបំពេញទៅតាមច្បាប់ ឬសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឲ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្តល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀត ដែលមានទំនាក់ទំនងញាតិនឹងគ្នា ឲ្យអាចរស់នៅក្នុងសង្គម មានន័យថា ជាការជួយគ្នារវាងអ្នកដែលមានទំនាក់ទំនងញាតិនឹងគ្នា ចំពោះបុគ្គលដែលមិនអាចទ្រទ្រង់ជីវភាពខ្លួនបាន។ អាហារកាតព្វកិច្ច គឺជាជំនួយផ្នែកហិរញ្ញវត្ថុ ឬសម្ភារៈផ្សេងៗ ដែលត្រូវផ្តល់ដោយ ជនត្រូវផ្តល់អាហារកាតព្វកិច្ច ហៅថា ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ដល់បុគ្គលជាញាតិ ហៅថា ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចដែលមិនអាចទ្រទ្រង់ជីវភាពខ្លួនឯងបាន ហើយបុគ្គលនោះមានសិទ្ធិទទួលការផ្គត់ផ្គង់អាហារកាតព្វកិច្ចតាមលក្ខខណ្ឌកំណត់។

ជាក់ស្តែងអាហារកាតព្វកិច្ច គឺត្រូវបានផ្តល់ដោយបុគ្គលដែលមានករណីយកិច្ចផ្គត់ផ្គង់ និងមានលទ្ធភាពនៅក្នុងការផ្តល់ចំពោះជនដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច។ ជនដែលទទួលបានអាហារកាតព្វកិច្ចអាចជា ញាតិរបស់ខ្លួន ដែលគ្មានលទ្ធភាព ឬមួយធនធាននៅក្នុងការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ដូចជា កង្វះសំលៀកបំពាក់ អាហារ លំនៅដ្ឋាន សុខុមាលភាព និងការទទួលបាននូវការអប់រំជាដើម។ ជាងនេះទៅទៀតអាហារកាតព្វកិច្ច ដែលអាចក្លាយជាចំនួនទឹកប្រាក់នៃការទ្រទ្រង់ជីវភាព សម្រាប់បុគ្គលដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច គឺជាចំនួនទឹកប្រាក់ដែលនៅសេសសល់ បន្ទាប់ពីបុគ្គលដែលមានករណីយកិច្ចត្រូវទទួលបន្ទុកអាហារកាតព្វកិច្ច បានចំណាយសម្រាប់ជីវភាពគ្រួសារ ប្រពន្ធ កូន ចំណាយជាប្រចាំផ្ទាល់ខ្លួន ទៅតាមឋានៈក្នុងសង្គម ហើយចំនួនដែលនៅសេសសល់នឹងក្លាយជាកម្មវត្ថុនៃអាហារកាតព្វកិច្ច។ ដូចជាឪពុកម្តាយ មានករណីយកិច្ច ត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់កូនដែលជាអនីតិជន នៅក្នុងការចិញ្ចឹមបីបាច់ថែរក្សា ផ្តល់នូវការអប់រំ និង ជួយផ្តល់នូវតម្រូវការចាំបាច់ផ្សេងៗ។

### ១.១.២ ប្រភេទនៃអាហារកាតព្វកិច្ច

អាហារកាតព្វកិច្ចត្រូវបានបែងចែកជា ៤ប្រភេទ រួមមាន៖

ក. អាហារកាតព្វកិច្ចតាមផ្លូវច្បាប់

អាហារកាតព្វកិច្ចតាមផ្លូវច្បាប់ ជាអាហារកាតព្វកិច្ចដែលមានកំណត់ក្នុងច្បាប់ ដូចជា ក្រមរដ្ឋប្បវេណីដែលកំណត់អំពីកាតព្វកិច្ចរវាងប្តីប្រពន្ធចំពោះគ្នា ដោយប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ

និងសង្គ្រោះគ្នាទៅវិញទៅមក[1]។ ឧបមាថា បុរស ក បានរៀបអាពាហ៍ពិពាហ៍ជាមួយនារី ខ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ អ្នកទាំងពីរបានសន្យារួមរស់ និងប្រកបអាជីវកម្មជាមួយគ្នារហូតដល់ចាស់ស្លាប់។ ដូច្នេះហើយ បុរស ក និងនារី ខ ត្រូវជួយគ្នាទៅវិញទៅមក លើគ្រប់វិស័យ និងមើលថែទាំគ្នា។

មួយវិញទៀត រដ្ឋធម្មនុញ្ញ ក៏បានកំណត់អំពី ឪពុកម្តាយដែលមានកាតព្វកិច្ចចិញ្ចឹមថែរក្សាកូន និងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ[2] ផងដែរ។ ពោលគឺឪពុកម្តាយ មានករណីយកិច្ចត្រូវស្រឡាញ់កូន ចិញ្ចឹមបីបាច់ថែរក្សាកូន និងយកចិត្តទុកដាក់អប់រំកូន ដោយបណ្តុះបណ្តាលឲ្យកូនស្រឡាញ់ការរៀនសូត្រ ស្នេហាមាតុភូមិ មានស្មារតីសាមគ្គីអន្តរជាតិ ស្រឡាញ់ពលកម្ម គោរពទ្រព្យសម្បត្តិរដ្ឋ និងទ្រព្យសម្បត្តិរបស់អ្នកដទៃ។

ខ. អាហារកាតព្វកិច្ចតាមការព្រមព្រៀង

អាហារកាតព្វកិច្ចតាមការព្រមព្រៀង សំដៅទៅលើអាហារកាតព្វកិច្ច ដែលកើតចេញពីការព្រមព្រៀងរវាងភាគីទាំងសងខាង គឺជនមានករណីយកិច្ចផ្តត់ផ្គង់អាហារកាតព្វកិច្ច និងជនមានសិទ្ធិទទួលអាហារកាតព្វកិច្ច។ ដោយអាហារកាតព្វកិច្ចតាមការព្រមព្រៀង គឺបានកំណត់នូវកម្មវត្ថុជាក់លាក់ អាចជាទីកន្លែងស្នាក់នៅ ជាថវិកា ម្ហូបអាហារ ឬ សម្ភារៈផ្សេងៗ សម្រាប់ជួយសម្រួលដល់ការរស់នៅ របស់ជនមានសិទ្ធិទទួលអាហារកាតព្វកិច្ច ពីអ្នកដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ក្នុងរយៈពេលសមស្របមួយ។ លើសពីនេះទៅទៀត ប្រសិនបើជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច មានច្រើននាក់ ជនទាំងនោះត្រូវកំណត់ជាក់លាក់អំពីជនម្នាក់ ឬ ច្រើននាក់ ដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ដោយការពិភាក្សា។[3] ឧបមាថា ក មានទំនាក់ទំនងញាតិនឹង ខ។ ក គឺជាអ្នកមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ហើយ ខ ជាជនមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច។ នៅពេលដែល ក និង ខ បានព្រមព្រៀងគ្នា ចំពោះការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ ឬជំនួយផ្សេងៗទៀតជាអាទិ៍ នោះហើយជាអាហារកាតព្វកិច្ចតាមការព្រមព្រៀង។

គ. អាហារកាតព្វកិច្ចតាមផ្លូវតុលាការ

អាហារកាតព្វកិច្ចតាមផ្លូវតុលាការ គឺកើតចេញពីការដាក់ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់អាហារកាតព្វកិច្ច របស់អ្នកមានសិទ្ធិទទួលអាហារកាតព្វកិច្ចទៅកាន់តុលាការ បន្ទាប់ពីអាហារកាតព្វកិច្ចដោយការព្រមព្រៀង ពុំអាចកើតមានឡើងដោយប្រការណាមួយ។ ដោយតុលាការ ជាអ្នកមានសមត្ថកិច្ចក្នុងការកំណត់ជនដែលត្រូវផ្គត់ផ្គង់ អាហារកាតព្វកិច្ចជាក់លាក់ ដោយគិតពិចារណាទៅលើលទ្ធភាពទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត របស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ទំនាក់ទំនងបុគ្គលរបស់ភាគី និង

[1] មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាចក្រកម្ពុជាឆ្នាំ២០០៧

[2] មាត្រា ៤៧ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា១៩៩៣

[3] មាត្រា ១១៤១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ស្ថានភាពផ្សេងទៀតទាំងអស់។[4] នៅពេលដីកាសម្រេច បានចូលជាស្ថាពរ ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវតែអនុវត្តទៅតាមខ្លឹមសារនៃដីកាសម្រេចនោះ។

ឃ. អាហារកាតព្វកិច្ចតាមទំនៀមទម្លាប់

អាហារកាតព្វកិច្ចតាមទំនៀមទម្លាប់ គឺកើតចេញពីការអនុវត្តតៗគ្នាពីមួយជំនាន់ទៅមួយជំនាន់ ឬ អាចជាវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ដែលមនុស្សគ្រប់រូបមែងតែងតែបំពេញ និងជួយគ្នាទៅវិញទៅមក។ ជាងនេះទៅទៀត បើផ្អែកលើស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរា តាមទំនៀមទម្លាប់។[5] មានន័យថាការចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរា គឺត្រូវបានអនុវត្តតាំងពីយូរណាស់មកហើយ រហូតប្រែក្លាយទៅជាទំនៀមទម្លាប់ ដែលគេតែងតែអនុវត្តរហូតដល់ពេលបច្ចុប្បន្ន។

ដូចជា ការមើលថែរក្សាឪពុកម្ដាយ ជីដូនជីតា និង ញាតិ នៅពេលពួកគាត់ចម្រើនវ័យចាស់ជរា ឬមួយនៅពេលពួកគាត់មានជម្ងឺឈឺស្កាត់ ដែលជាកាតព្វកិច្ចរបស់ បងប្អូន កូន ចៅ ក្នុងការមើលថែទាំសុខភាព និងផ្គត់ផ្គង់ការរស់នៅដ៏ល្អមួយសម្រាប់ពួកគាត់។

### ១.១.៣ លក្ខខណ្ឌនៃការអនុវត្តការផ្គត់ផ្គង់អាហារកាតព្វកិច្ច

អាហារកាតព្វកិច្ច មិនអាចត្រូវបានផ្ដល់ចំពោះគ្រប់បុគ្គលដែលអះអាង ថាចង់ទទួលបានការផ្គត់ផ្គង់ក៏ចេះទទួលបាននោះទេ។ គោលបំណងដ៏ធំបំផុតរបស់អាហារកាតព្វកិច្ច គឺការជួយសង្គ្រោះបុគ្គលដែល អសមត្ថភាពនៅក្នុងការប្រកបរបរចិញ្ចឹមជីវិតរបស់ខ្លួនពិតប្រាកដ។ អាស្រ័យហេតុនេះហើយ អាហារកាតព្វកិច្ច អាចត្រូវបានអនុវត្ត លុះត្រាតែបំពេញនូវលក្ខខណ្ឌទាំងពីរខាងក្រោមនេះ៖

លក្ខខណ្ឌទី១ គឺជនដែលមានសិទ្ធិទាមទារអាហារកាតព្វកិច្ច ត្រូវស្ថិតក្នុងស្ថានភាពក្រីក្រ លំបាកហើយខ្លួនគ្មានលទ្ធភាព អាចផ្គត់ផ្គង់ជីវភាពខ្លួនឯងបានទាំងស្រុង ឬមួយផ្នែក ដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬសមត្ថភាពនៃការធ្វើការងារដោយខ្លួនឯង និងត្រូវមានបន្ទុកបង្ហាញភស្តុតាងពីអលទ្ធភាពក្នុងការផ្គត់ផ្គង់ជីវភាពរស់នៅខ្លួនឯង។ នោះមានន័យថា ជននោះពិតជាលំបាកនៅក្នុងការចិញ្ចឹមជីវិតខ្លួនឯងពិតប្រាកដមែន ទើបចាំបាច់ត្រូវការជំនួយនៅក្នុងការទ្រទ្រង់ដល់ការរស់នៅឲ្យបានសមរម្យមួយ។ ដើម្បីអាចធានាបានថាបុគ្គលនោះពិតជាអលទ្ធភាពពិតមែន បុគ្គលនោះត្រូវភ្ជាប់ជាមួយនឹងភស្តុតាង ដែលអាចបញ្ជាក់ថាខ្លួនពិតជាអសមត្ថភាពក្នុងការចិញ្ចឹមជីវិតដោយខ្លួនឯងមែន។

[4] មាត្រា ១១៤១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[5] មាត្រា ៤៧ កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

លក្ខខណ្ឌទី២ គឺជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវមានលទ្ធភាព ឬមធ្យោបាយហិរញ្ញវត្ថុ អាចផ្តល់ជំនួយសង្គ្រោះបាន មានន័យថា បុគ្គលដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ផ្តល់ដល់បុគ្គលដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ចនោះ។ មិនមែនឲ្យតែបុគ្គលនោះជាបុគ្គលដែលមានករណីយកិច្ច សុទ្ធសឹងតែត្រូវបំពេញនូវកាតព្វកិច្ចរបស់ខ្លួន ទាំងដែលខ្លួនពុំមានលទ្ធភាពគ្រប់គ្រាន់នោះទេ។

ឧបមាថា៖ ក ជាបុគ្គលដែលមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ច សម្រាប់ទ្រទ្រង់ជីវភាពរស់នៅ ដល់ ខ ជាអ្នកមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច ដែលជាក្មួយហើយជាកូនកំព្រា។ នៅក្នុងករណីនេះ ប្រសិនបើ ក មានលទ្ធភាពគ្រប់គ្រាន់ ក្រោយពីប្រើប្រាស់សម្រាប់ការចំណាយទៅលើគ្រួសាររបស់ខ្លួនរួចរាល់អស់ហើយ ប្រាក់ដែលនៅសេសសល់ពីការចំណាយ នៅសល់សមរម្យនោះ ក អាចផ្តល់ជាអាហារកាតព្វកិច្ចដល់ ខ ជាក្មួយដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចបាន។ ផ្ទុយទៅវិញ ប្រសិនបើប្រាក់ដែល ក បានប្រើប្រាស់សម្រាប់ការចំណាយលើការផ្គត់ផ្គង់សម្រាប់ក្រុមគ្រួសាររបស់ខ្លួនពុំគ្រប់គ្រាន់ ឬមួយសេសសល់បន្តិចបន្តួច នោះ ក ក៏មិនអាចផ្តល់នូវប្រាក់ដល់ ខ ដែលជាក្មួយរបស់ខ្លួននោះបានផងដែរ។ នោះមានន័យថាបើទោះបីជាបុគ្គលនោះមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ច តាមច្បាប់កំណត់ក៏ពិតមែន ប៉ុន្តែប្រសិនបើបុគ្គលនោះឯងមិនមានលទ្ធភាពគ្រប់គ្រាន់ ការផ្តល់អាហារកាតព្វកិច្ចក៏មិនអាចកើតមានចំពោះបុគ្គលនោះបានដែរ។

### ១.១.៤ លក្ខណៈនៃអាហារកាតព្វកិច្ច

ចំពោះលក្ខណៈរបស់អាហារកាតព្វកិច្ច គឺជាសិទ្ធិផ្តាច់មុខផ្ទាល់របស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច មានន័យថា ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចអាចទទួលបានដោយចំពោះ សម្រាប់ខ្លួនឯងផ្ទាល់តែប៉ុណ្ណោះ។[6]

អាហារកាតព្វកិច្ច មិនអាចជាកម្មវត្ថុនៃអនុប្បទាន ប្រទានកម្ម ឬការបង្កើតសិទ្ធិប្រាតិភោគសម្រាប់តតិយជន ឬជំនួញផ្សេងៗទៀតបានឡើយ សូម្បីតែធ្វើអនុប្បទានទៅជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចផ្សេង ឬជនដែលមានប្រយោជន៍ផ្សេងទៀត។[7] ជារួម អាហារកាតព្វកិច្ច គឺត្រូវបានផ្តល់ឱ្យទៅជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចតែម្នាក់តែប៉ុណ្ណោះ មិនអាចធ្វើជាកម្មវត្ថុសម្រាប់ផ្ទេរឲ្យអ្នកដទៃបាននោះទេ។

អាហារកាតព្វកិច្ចមានអានុភាពឆ្ពោះទៅអនាគត មិនអាចទាមទារអាហារកាតព្វកិច្ច ដែលកើតមានក្នុងអតីតកាលបានទេ មានន័យថាជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចមិនអាចទាមទារឲ្យ អ្នកដែលមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ចចំពោះអតីតកាលបាននោះទេ។

[6] មាត្រា ១១៤៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[7] មាត្រា ១១៤៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

អាហារកាតព្វកិច្ច មិនអាចត្រូវបានរឹបអូស[8] ដោយហេតុថា អាហារកាតព្វកិច្ច គឺជាជំនួយសម្រាប់តែជនក្រីក្រប៉ុណ្ណោះ ហើយមានគោលបំណង ការពារ និងទ្រទ្រង់ជីវភាពរបស់អ្នកមានសិទ្ធិទទួលអាហារកាតព្វកិច្ចផ្ទាល់ ដូចជា ការផ្តល់ប្រាក់ឧបត្ថម្ភផ្នែកសិក្សា ប្រាក់ឧបត្ថម្ភផ្នែកសុខភាព ឬប្រាក់ឧបត្ថម្ភសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់អ្នកមានសិទ្ធិទទួលអាហារកាតព្វកិច្ច។

អាហារកាតព្វកិច្ច មិនអាចធ្វើឧបាទេសកម្មបាន[9] មានន័យថាប្រសិនបើតុលាការចេញដីកាសម្រេចឲ្យបុគ្គលណាដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច បុគ្គលនោះឯងគឺត្រូវបំពេញនូវកាតព្វកិច្ច ដែលជាការកំណត់នៅក្នុងសេចក្តីសម្រេចដោយខានពុំបាន។ ប៉ុន្តែ ករណីដែលអ្នកមានសិទ្ធិទទួលអាហារកាតព្វកិច្ចមានជាប់បំណុលជាមួយនឹងម្ចាស់បំណុលដែលជាតតិយជន តតិយជននោះឯង មិនអាចធ្វើការទាមទារសិទ្ធិលើបំណុល ដោយផ្អែកលើអាហារកាតព្វកិច្ចបាននោះទេ។

អាហារកាតព្វកិច្ច មិនអាចធ្វើសន្តតិកម្មបន្តបានទេ[10] ដោយសារតែអាហារកាតព្វកិច្ច បានកំណត់ជនដែលមានករណីយកិច្ចផ្គត់ផ្គង់ជាក់លាក់ ហើយការផ្គត់ផ្គង់អាហារកាតព្វកិច្ចជាករណីយកិច្ចផ្តាច់មុខទាំងស្រុងរបស់ជនដែលមានករណីយកិច្ច ហេតុដូច្នេះសន្តតិជនមិនអាចផ្គត់ផ្គង់បន្តបានទេ។ មានន័យថា ប្រសិនបើអ្នកមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ទទួលមរណភាព ការផ្គត់ផ្គង់អាហារកាតព្វកិច្ច មិនត្រូវបានផ្ទេរបន្តឲ្យមកកូនរបស់អ្នកមានករណីយកិច្ចទទួលផ្គត់ផ្គង់បន្តនោះទេ គឺតុលាការត្រូវធ្វើការស្វែងរក និងកំណត់អ្នកមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចថ្មី។

## ១.២ ជនដែលពាក់ព័ន្ធក្នុងការទាមទារអាហារកាតព្វកិច្ច

ជាទូទៅដើម្បីទាមទារ និងទទួលបានអាហារកាតព្វកិច្ច ចាំបាច់ត្រូវមានភាគីដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច និងភាគីដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច។

### ១.២.១ បុគ្គលដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច

ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច សំដៅដល់បុគ្គលដែលត្រូវផ្តល់អាហារកាតព្វកិច្ច ដល់ញាតិដែលមិនអាចទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួនបាន។ ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច អាចផ្តល់ជាថវិកា ឬសម្ភារៈផ្សេងៗទៀត ឱ្យទៅញាតិដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច តាមមធ្យោបាយសមស្របណាមួយ ក្នុងករណីដែលជននោះអលទ្ធភាព មិនអាចចិញ្ចឹមខ្លួនឯងបាន ទោះបីនៅក្នុងកម្រិតអប្បបរមាក៏គាត់មិនមានលទ្ធភាព។

[8] មាត្រា ៣៨២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦
[9] មាត្រា ៤២២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[10] មាត្រា ១១៤៧ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ថ្វីត្បិតអ្នកដែលមានទំនាក់ទំនងញាតិ តាមដែលច្បាប់បានកំណត់ ត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចក៏ដោយ ក៏មិនមានន័យថា គ្រប់ទំនាក់ទំនងញាតិទាំងអស់ សុទ្ធតែត្រូវផ្តល់អាហារកាតព្វកិច្ចនោះទេ។ ជាគោលការណ៍លំដាប់នៃជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចមានដូចតទៅៈ លំដាប់ទី១ គឺញាតិដែលរស់នៅជាមួយគ្នា លំដាប់ទី២ គឺញាតិលោហិតខ្សែផ្ទាល់ និងបងប្អូនបង្កើត ស្ថិតក្នុងលំដាប់ទី៣។[11] ការកំណត់លំដាប់ មានន័យថា ការទទួលបន្ទុកអាហារកាតព្វកិច្ច គឺគិតរាប់ចាប់ពីលំដាប់ទី១ មកមុន បើគ្មានញាតិក្នុងលំដាប់ទី១ទេ ត្រូវកំណត់យកញាតិតាមលំដាប់ទី២ ឬបើគ្មានញាតិក្នុងលំដាប់ទី២ទេ ត្រូវកំណត់យកញាតិតាមលំដាប់បន្តបន្ទាប់ទៀត។

ចំពោះអញ្ញាត្តកម្មវិញ ជនដែលស្ថិតក្នុងទំហំញាតិថ្នាក់ទី៣នឹងជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច តុលាការមានឆន្ទានុសិទ្ធិ ក្នុងការតែងតាំងជនទាំងនេះជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន ប្រសិនបើមានស្ថានភាពពិសេស។[12] លើសពីនេះទៅទៀត ប្រសិនបើជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច មានច្រើននាក់ ជនទាំងនោះត្រូវពិភាក្សាគ្នា ដើម្បីកំណត់អំពីជនដែលត្រូវផ្គត់ផ្គង់ឱ្យបានជាក់លាក់។[13] ប៉ុន្តែបើការពិភាក្សានោះពុំបានសម្រេច តុលាការត្រូវកំណត់ជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចជាក់លាក់ ដោយគិតពិចារណាទៅលើលទ្ធភាពទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច និងស្ថានភាពផ្សេងទៀតទាំងអស់។[14]

ក. ញាតិដែលរស់នៅជាមួយគ្នា

ញាតិដែលរស់នៅជាមួយគ្នា សំដៅដល់ញាតិ ដែលកំពុងរស់នៅក្រោមដំបូលផ្ទះតែមួយដូចគ្នា។ ញាតិដែលរស់នៅជាមួយគ្នា គឺជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចស្ថិតក្នុងលំដាប់ទី១។ មានន័យថា ញាតិដែលរស់នៅជាមួយនឹងជនដែលមិនអាចទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន ត្រូវក្លាយជាអ្នកផ្គត់ផ្គង់អាហារកាតព្វកិច្ចមុនគេ[15]។ ឧបមាថា លោកស្រី ក ជាជនក្រីក្រ និងចាស់ជរាម្នាក់ មិនអាចចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួនបានទេ ហើយសព្វថ្ងៃលោកស្រីរស់នៅជាមួយចៅប្រុសម្នាក់។ ករណីនេះ ចៅប្រុសរបស់លោកស្រី ក ត្រូវក្លាយជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចលំដាប់ទី១ ដល់លោកស្រី ក ប្រសិនបើលោកបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ ដើម្បីក្លាយជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច។

[11] មាត្រា១១៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[12] មាត្រា១១៤០ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[13] មាត្រា១១៤១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[14] មាត្រា១១៤១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[15] មាត្រា១១៤០ ចំណុចទី១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ខ. ញាតិលោហិតខ្សែផ្ទាល់

ញាតិលោហិតខ្សែផ្ទាល់ សំដៅដល់ញាតិដែលមានឈាមជ័រជាមួយគ្នា ហើយកើតតគ្នាពីមួយទៅមួយតាមលំដាប់ រួមមានប្រាំមួយថ្នាក់ គឺបុព្វញាតិ[16] និង បច្ឆាញាតិ[17] ។

ញាតិលោហិតខ្សែផ្ទាល់ គឺស្ថិតក្នុងលំដាប់ទី២ នៃជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច បន្ទាប់ពីញាតិដែលរស់នៅជាមួយគ្នា។ ប្រសិនបើញាតិដែលរស់នៅជាមួយគ្នា ដែលស្ថិតក្នុងលំដាប់ទី១ មិនអាចបំពេញលក្ខខណ្ឌគ្រប់គ្រាន់ ដើម្បីក្លាយជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចបានទេ នោះសិទ្ធិដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវធ្លាក់មកលើជនដែលមានលំដាប់ទី២ គឺញាតិលោហិតខ្សែផ្ទាល់[18]។ ឧបមាថា លោកស្រី ក ជាជនក្រីក្រ និងចាស់ជរាម្នាក់ មិនអាចចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួនបានទេ សព្វថ្ងៃលោកស្រីរស់នៅជាមួយចៅប្រុសម្នាក់ ហើយលោកស្រីមាន កូនស្រីម្នាក់រស់នៅក្រៅប្រទេស។ ប៉ុន្តែដោយសារ ចៅប្រុសរបស់លោកស្រីពុំអាចបំពេញលក្ខខណ្ឌគ្រប់គ្រាន់ ដើម្បីក្លាយជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន ក្នុងករណីនេះ កូនស្រីរបស់លោកស្រី ក ត្រូវក្លាយជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចលំដាប់ទី២ ដល់លោកស្រី ក ប្រសិនបើកូនស្រីរបស់លោកស្រីបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីក្លាយជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច។

គ. បងប្អូនបង្កើត

បងប្អូនបង្កើត ជាញាតិដែលកើតចេញពីឪពុកម្តាយរួមជាមួយគ្នា ឬ រួមតែឪពុក ឬ រួមតែម្តាយ ឬ កូនសុំជាអាទិ៍។ បងប្អូនបង្កើត គឺស្ថិតក្នុងលំដាប់ទី៣ នៃជនដែលមានករណីយកិច្ច ត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច បន្ទាប់ពីញាតិដែលរស់នៅជាមួយគ្នា និងញាតិលោហិតខ្សែផ្ទាល់។ ដូចគ្នាដែរ ប្រសិនបើញាតិដែលរស់នៅជាមួយគ្នា និងញាតិលោហិតខ្សែផ្ទាល់ ដែលស្ថិតក្នុងលំដាប់ទី១ និងទី២ មិនអាចបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីក្លាយជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចបានទេ នោះការផ្គត់ផ្គង់អាហារកាតព្វកិច្ចត្រូវធ្លាក់មកលើបងប្អូនបង្កើតដែលស្ថិតក្នុងលំដាប់ទី៣[19]។ ឧបមាថា លោកស្រី ក ខាងលើដែល ជាជនក្រីក្រ និងចាស់ជរាម្នាក់ មិនអាចចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួនបានទេ សព្វថ្ងៃលោកស្រីរស់នៅជាមួយចៅប្រុសម្នាក់ ហើយលោកស្រី មានកូនស្រីម្នាក់រស់នៅក្រៅប្រទេស និងប្អូនប្រុស២នាក់ទៀត រស់នៅទីក្រុង។ ប៉ុន្តែដោយសារ ចៅប្រុស និងកូនស្រីរបស់លោកស្រី ពុំអាចបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីក្លាយជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន នោះប្អូនប្រុស២នាក់ទៀតរបស់លោកស្រី ក ត្រូវក្លាយជាជន

[16] ឪពុកម្តាយ ជីដូនជីតា ជីទួត ជីលួត ជីលា និងជីប៉ា

[17] កូនបង្កើត ចៅ ចៅទួត ចៅលួត ចៅលា និងចៅប៉ា

[18] មាត្រា១១៤០ ចំណុចទី២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[19] មាត្រា១១៤០ ចំណុចទី៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចលំដាប់ទី៣ ដល់លោកស្រី ក ប្រសិនបើប្អូនប្រុសរបស់លោកស្រីទាំង២ បានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីក្លាយជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច។

ឃ. ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចតាមសេចក្ដីសម្រេចរបស់តុលាការ

ដោយយោងក្រមរដ្ឋប្បវេណី មាត្រា១១៤០ កថាខណ្ឌទី២ ជនដែលមានករណីយកិច្ច ផ្គត់ផ្គង់អាហារកាតព្វកិច្ចតាមសេចក្ដីសម្រេចរបស់តុលាការ គឺញាតិក្នុងថ្នាក់ទី៣ ក្នុងករណីមានស្ថានភាពពិសេសណាមួយ។

ដើម្បីអាចកំណត់អំពីញាតិក្នុងថ្នាក់ទី៣បាន យើងគួរស្វែងយល់ពីការគណនាថ្នាក់ញាតិ។

ការគណនាថ្នាក់ញាតិមានពីរគឺ ការគណនាថ្នាក់ញាតិផ្ទាល់ និងការគណនាថ្នាក់សាខាញាតិ។[20] ចំពោះការគណនាថ្នាក់ញាតិផ្ទាល់ ត្រូវកំណត់ដោយគណនាចំនួននៃតំណពូជរវាងញាតិ។[21] ចំណែកឯ ការគណនាថ្នាក់សាខាញាតិ ត្រូវគណនាចំនួននៃតំណពូជ គិតចាប់ពីជននោះ ឬសហព័ទ្ធរបស់ជននោះ ឡើងទៅដល់បុព្វជនដូចគ្នា និងចំនួននៃតំណពូជ គិតចាប់ពីបុព្វជនរបស់ជននោះ ចុះរហូតមកដល់ជនម្នាក់ទៀត។[22] ញាតិក្នុងថ្នាក់ទី៣ អាចជា ពូមីង ក្មួយ ជីដូនជីតាទួត របស់សាមីខ្លួន ឬរបស់សហព័ទ្ធខ្លួន។ ចំពោះតារាងថ្នាក់ញាតិមាននៅក្នុងឧបសម្ព័ន្ធទី១។

ម៉្យាងវិញទៀត ញាតិក្នុងបីថ្នាក់ អាចមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចតាមសេចក្ដីសម្រេចរបស់តុលាការ លុះត្រាតែក្នុងករណីមានស្ថានភាពពិសេស។ ដោយស្ថានភាពពិសេស អាចកើតមានក្នុងករណីដែលជនមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច ពុំមានញាតិក្នុងលំដាប់ទាំង៣ ដូចជាញាតិដែលរស់នៅជាមួយគ្នា ញាតិលោហិតខ្សែផ្ទាល់ និងបងប្អូនបង្កើត ឬក៏មានដែរ តែមិនអាចផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន ឬប្រសិនបើផ្គត់ផ្គង់អាហារកាតព្វកិច្ចអាចបណ្ដាលឱ្យធ្លាក់ខ្លួនក្រ ឬញាតិដែលមានកំណត់ខាងលើទាំង៣លំដាប់ មិនអាចទំនាក់ទំនងបាន ឬបាត់ខ្លួន។ ប្រសិនស្ថិតក្នុងស្ថានភាពពិសេសបែបនេះ នោះករណីយកិច្ចក្នុងការផ្គត់ផ្គង់អាហារកាតព្វកិច្ច នឹងត្រូវធ្លាក់ទៅលើ ញាតិនៅក្នុងថ្នាក់ទី៣។ ឧបមាថា លោក ក រស់នៅតែម្នាក់ឯង ពុំមានកូន ហើយបងប្អូនរបស់លោក ក បានស្លាប់អស់ លោក ក នៅសល់តែក្មួយស្រីម្នាក់ដែលមានជីវភាពធូរធារ ត្រូវជាកូនរបស់បងប្រុសបង្កើតរបស់ខ្លួន ហើយលោក ក ពុំមានសមត្ថភាពក្នុងការចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ខ្លួនបានទេ ព្រោះគាត់បានជួបគ្រោះថ្នាក់ចរាចរណ៍ និងក្លាយជាជនពិការអស់មួយជីវិត។ ករណីនេះ លោក ក អាចដាក់ពាក្យសុំទៅតុលាការទាមទារឱ្យក្មួយស្រី ជាញាតិថ្នាក់ទី៣ ផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់ខ្លួនបាន។

[20] មាត្រា៩៣៩ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[21] មាត្រា៩៣៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[22] មាត្រា៩៣៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ចំពោះប្រភេទទីពីរ ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចតាមសេចក្ដីសម្រេចរបស់តុលាការ គឺសហព័ទ្ធដែលនៅរស់ ឬញាតិរបស់សហព័ទ្ធដែលស្លាប់ ក្នុងករណីដែលអាពាហ៍ពិពាហ៍បានរលាយដោយសារមរណភាពរបស់សហព័ទ្ធម្ខាង។[23] អាពាហ៍ពិពាហ៍ត្រូវបានរលាយ ដោយសារការស្លាប់របស់សហព័ទ្ធម្ខាង អាហារកាតព្វកិច្ចរវាងញាតិ នៅតែមានអត្ថិភាពរវាងសហព័ទ្ធដែលនៅរស់ជាមួយនឹងញាតិរបស់សហព័ទ្ធដែលបានទទួលមរណភាព លើកលែងតែសហព័ទ្ធដែលនៅរស់បានរៀបអាពាហ៍ពិពាហ៍ថ្មី ឬបង្ហាញឆន្ទៈផ្ដាច់ទំនាក់ទំនងញាតិពន្ធតាមផ្លូវតុលាការ[24]។ ឧបមាថា ក្រោយពេលប្ដីរបស់នារីបានស្លាប់ទៅ នារីត្រូវរស់នៅតែម្នាក់ឯង ពុំមានកូន ហើយក៏គ្មានបងប្អូន សាច់ញាតិណាទាំងអស់។ នារីពុំទាន់បានរៀបអាពាហ៍ពិពាហ៍ថ្មីនៅឡើយទេ មួយវិញទៀត នាងបានធ្លាក់ខ្លួនក្រ គ្មានសមត្ថភាពក្នុងការចិញ្ចឹមជីវិតនោះទេ។ ប៉ុន្តែ នារីនៅមានបូរ៉ា ដែលត្រូវជាក្មួយប្រុសរបស់ប្ដីខ្លួន។ នារីអាចដាក់ពាក្យសុំទៅតុលាការដើម្បីទាមទារអាហារកាតព្វកិច្ច ពីបូរ៉ាបាន ព្រោះអាពាហ៍ពិពាហ៍រវាងនារី ជាមួយប្ដីដែលបានស្លាប់ បានរលាយដោយសារមរណភាពរបស់សហព័ទ្ធម្ខាង។ ជាហេតុនាំឱ្យ អាហារកាតព្វកិច្ចរវាងញាតិ នៅតែមានអត្ថិភាពរវាងនារី នឹងបូរ៉ា។

### ១.២.២ បុគ្គលដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច

យោងតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា អាហារកាតព្វកិច្ច គឺជាជំនួយផ្នែកហិរញ្ញវត្ថុដល់បុគ្គលដែលមិនអាចទ្រទ្រង់ជីវភាពដោយសមត្ថភាពផ្ទាល់ខ្លួនបាន។ បុគ្គលដែលត្រូវការអាហារកាតព្វកិច្ច គឺជាជនដែលមិនអាចទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួនបាន សូម្បីតែក្នុងកម្រិតទាបបំផុត ដែលក្នុងពាក្យច្បាប់ត្រូវបានគេហៅថា ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច។ លើសពីនេះទៅទៀត ប្រសិនបើជនមានសិទ្ធិទទួលអាហារកាតព្វកិច្ចមានច្រើននាក់ ហើយលទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចពុំគ្រប់គ្រាន់ ក្នុងការផ្គត់ផ្គង់ចំពោះជនទាំងនោះទេ នោះពួកគេត្រូវធ្វើការពិភាក្សា ដើម្បីកំណត់អំពីជនដែលត្រូវទទួលអាហារកាតព្វកិច្ចឱ្យបានជាក់លាក់។[25] ប៉ុន្តែបើការពិភាក្សានោះពុំបានសម្រេច តុលាការត្រូវកំណត់ ជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចឱ្យបានជាក់លាក់ ដោយគិតពិចារណាទៅលើលទ្ធភាពទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ទំនាក់ទំនងបុគ្គលរបស់ភាគី និងស្ថានភាពផ្សេងទៀតទាំងអស់។[26]

នៅក្នុងក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃ ពុំបានចែងលម្អិតពីជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចនោះទេ ពោលគឺចែងតែជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចតែ

[23] មាត្រា១១៤០ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[24] មាត្រា៩៨១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[25] មាត្រា១១៤១ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[26] មាត្រា១១៤១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ប៉ុណ្ណោះ។ ជាហេតុអាចនាំឱ្យយើង អាចទាញការសន្និដ្ឋានដោយយកបញ្ញត្តិនៃជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច មកកំណត់រកជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចបានថា ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចបាន លុះត្រាតែខ្វះខាតផ្នែកជីវភាព មានទំនាក់ទំនងញាតិជាមួយអ្នកមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច និងអាចបង្ហាញឆន្ទៈ ឬទាមទារតាមផ្លូវតុលាការ ឬសុំរក្សាការពារដើម្បីទ្រទ្រង់ជីវភាពរស់នៅអប្បបរមា។

ក. បុគ្គលខ្វះខាតផ្នែកជីវភាព

ដើម្បីអាចក្លាយទៅជាជនដែលទទួលអាហារកាតព្វកិច្ចបាន លុះត្រាតែជននោះខ្វះខាតផ្នែកជីវភាព ពោលសំដៅដល់ជនដែលមិនអាចទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួនបាន ដូចជាមិនមានថវិកាសម្រាប់ចិញ្ចឹមជីវិត មិនអាចទិញអាហារបរិភោគដោយខ្លួនឯងបាន គ្មានសម្លៀកបំពាក់សមរម្យសម្រាប់ស្លៀកពាក់ គ្មានទីជម្រកសម្រាប់រស់នៅ គ្មានថវិកាផ្ទាល់ខ្លួនសម្រាប់ព្យាបាលជម្ងឺពេលឈឺស្កាត់ និងមិនអាចទទួលបានការអប់រំជាមូលដ្ឋាន ជាអាទិ៍។

ចំពោះការវាយតម្លៃ ទៅលើជនដែលខ្វះខាតផ្នែកជីវភាពខាងលើ ជាការវាយតម្លៃទូទៅលើតម្រូវការមូលដ្ឋានដែលចាំបាច់ និងខានពុំបានសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ ព្រមទាំងអាស្រ័យលើស្ថានភាពជាក់ស្តែង និងភស្តុតាងដែលអាចបង្ហាញជាក់ស្តែងថា បុគ្គលនោះពិតជាកំពុងខ្វះខាតពិតប្រាកដមែន។ ម្យ៉ាងវិញទៀត នៅកម្ពុជាសព្វថ្ងៃ ក៏ពុំទាន់មានប្រព័ន្ធនៃការវាយតម្លៃ ទៅលើជនដែលខ្វះខាតផ្នែកជីវភាពនៅឡើយទេ ដូច្នេះហើយការវាយតម្លៃនេះ គឺទុកសិទ្ធិឱ្យចៅក្រមជាអ្នកវិនិច្ឆ័យ។

ខ. មានទំនាក់ទំនងញាតិ ជាមួយអ្នកមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច

ដូចគ្នាដែរ ចំពោះជនដែលទទួលអាហារកាតព្វកិច្ច ក៏ត្រូវតែមានទំនាក់ទំនងជាញាតិនឹងជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចផងដែរ។ ជាក់ស្តែង ជនដែលទទួលអាហារកាតព្វកិច្ច ត្រូវតែជាញាតិរស់នៅជាមួយនឹងជនដែលមានករណីយកិច្ច ជាញាតិលោហិតខ្សែផ្ទាល់ និងជាបងប្អូនបង្កើតផងដែរ។[27]

ជនដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច មិនត្រូវបានកំណត់លំដាប់ដូចជនដែលមានករណីយកិច្ចនោះទេ មានន័យថាជនដែលទទួលអាហារកាតព្វកិច្ច អាចទទួលបានអាហារកាតព្វកិច្ចពីគ្រប់ញាតិដែលបានរៀបរាប់ខាងលើ ដោយពុំកំណត់លំដាប់ថាបុគ្គលដែលត្រូវទទួលបានអាហារកាតព្វកិច្ច លំដាប់ណាមួយត្រូវទទួលបានការផ្គត់ផ្គង់មុននោះទេ ប្រសិនបើមានការខ្វះខាត នឹងទទួលបានអាហារកាតព្វកិច្ចដូចៗគ្នា។ ជាង

[27] មាត្រា ១១៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

នេះទៅទៀត ញាតិក្នុង៣ថ្នាក់ ក៏មានសិទ្ធិទាមទារអាហារកាតព្វកិច្ចផងដែរ ក្នុងករណីដែលជនទទួលបានអាហារកាតព្វកិច្ចនោះ ពុំមានជនដែលមានករណីយកិច្ចដូចដែលបានរៀបរាប់ខាងលើ។[28]

គ. អាចបង្ហាញឆន្ទៈ ឬទាមទារតាមផ្លូវតុលាការ ឬសុំរក្សាការពារដើម្បីទ្រទ្រង់ជីវភាពរស់នៅជាអប្បបរមា

ចំពោះលក្ខខណ្ឌចុងក្រោយ ដើម្បីអាចក្លាយខ្លួនទៅជាជនដែលទទួលអាហារកាតព្វកិច្ចបាន គឺទាមទារឱ្យមានការបង្ហាញឆន្ទៈ ដោយការដាក់ពាក្យសុំទៅតុលាការ ឬសុំរក្សាការពារដើម្បីទ្រទ្រង់ជីវភាពរស់នៅជាអប្បបរមា។

ជាធម្មតា ដើម្បីអាចទទួលបានអាហារកាតព្វកិច្ច គឺទាមទារឱ្យមានការព្រមព្រៀង ដោយបង្ហាញឆន្ទៈរវាងជនដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច និងជនដែលមានករណីយកិច្ចផ្តត់ផ្គង់អាហារកាតព្វកិច្ច។ ប៉ុន្តែបើការព្រមព្រៀងមិនបានសម្រេចទេនោះ ក្រមរដ្ឋប្បវេណីបើកសិទ្ធិឱ្យបុគ្គលឯកជនដាក់ពាក្យសុំទាមទារតាមផ្លូវតុលាការបាន ដោយយោងលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។ ការធ្វើបែបនេះ គឺដើម្បីឱ្យតុលាការជាអ្នកកំណត់ អ្នកដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចជាក់លាក់ ដោយពិចារណាទៅលើលទ្ធភាពទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត របស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ទំនាក់ទំនងបុគ្គលរបស់ភាគី ជាដើម។

ម៉្យាងវិញទៀត ប្រសិនបើមានភាពចាំបាច់ បុគ្គលមានសិទ្ធិទទួលអាហារកាតព្វកិច្ច អាចដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ ដោយស្នើសុំឱ្យតុលាការចេញដីកាសម្រេចបង្គាប់ឱ្យចាត់ចែងជាបណ្តោះអាសន្ន[29] ដើម្បីធានាថានាពេលបច្ចុប្បន្ន ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច អាចទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួនបានបណ្តោះអាសន្នសិន។ នៅពេលដាក់ពាក្យសុំ ត្រូវភ្ជាប់ជាមួយនឹងសេចក្តីបញ្ជាក់ដំបូង។ ប្រសិនបើបានបំពេញគ្រប់លក្ខខណ្ឌអស់ហើយ តុលាការនឹងចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នតាមការស្នើសុំ។ ក្រោយមក បុគ្គលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ត្រូវដាក់ពាក្យសុំទាមទារឱ្យផ្តល់អាហារកាតព្វកិច្ច ដែលជាប្រភេទរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

[28] មាត្រា ១១៤០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[29] មាត្រា ៤៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

# ជំពូកទី ២
# នីតិវិធីនៃការទាមទារអាហារកាតព្វកិច្ច

## ២.១ ដំណាក់កាលនៃការដាក់ពាក្យសុំទាមទារអាហារកាតព្វកិច្ច

ដំណាក់កាលនៃការដាក់ពាក្យសុំទាមទារអាហារកាតព្វកិច្ច គឺជាចំណុចចាប់ផ្ដើមក្នុងការទាមទារអាហារកាតព្វកិច្ចតាមផ្លូវតុលាការ។

### ២.១.១ នីតិវិធីនៃការដាក់ពាក្យសុំ

ក. ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ

ជាការពិតណាស់ ដើម្បីឲ្យការដាក់ពាក្យសុំ ទៅតុលាការ មានប្រសិទ្ធភាពនឹងអាចធានាថាពាក្យសុំនោះត្រឹមត្រូវទៅតាមផ្លូវច្បាប់ គួរគប្បីស្វែងយល់អំពីចំណុចដែលចាំបាច់បំផុត និង ចំណុចណាដែលមិនគួរសរសេរនៅក្នុងពាក្យសុំនោះ។ ចំណុចដែលត្រូវសរសេរនៅក្នុងលិខិតនៃពាក្យសុំ មានដូចជា ឈ្មោះ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ និង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។[30] ជាងនេះទៅទៀត អ្នកដាក់ពាក្យសុំក៏ត្រូវសរសេរ ឈ្មោះ អាសយដ្ឋាន របស់បុគ្គលដែលខ្លួនបានទាមទារអាហារកាតព្វកិច្ចផងដែរ។ ការសរសេរឈ្មោះ និងអាសយដ្ឋានរបស់ភាគីឲ្យច្បាស់លាស់ គឺជាការចាំបាច់សម្រាប់បញ្ជាក់អត្តសញ្ញាណរបស់ភាគី សម្រាប់ធ្វើការជូនដំណឹងអំពីដីកាសម្រេច និងឯកសារផ្សេងៗដល់ភាគីទាំងសងខាង។ ចំពោះខ្លឹមសារ នៃដីកាសម្រេចបង្គាប់ឲ្យផ្ដល់អាហារកាតព្វកិច្ច ត្រូវផ្អែកលើពាក្យសុំទាមទារ អង្គហេតុ និងភស្តុតាងដែលភាគីដាក់ពាក្យសុំ បានដាក់ជូនតុលាការ។

ជាងនេះទៅទៀត ការដាក់ពាក្យសុំទាមទារអាហារកាតព្វកិច្ចនេះ ក៏អាចធ្វើឡើងដោយផ្ទាល់មាត់បានដែរ។ ដើម្បីអាចដាក់ពាក្យសុំដោយផ្ទាល់មាត់បាន អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្ដីថ្លែងការណ៍ចំពោះមុខក្រឡាបញ្ជីនូវចំណុចនីមួយៗដែលដូចគ្នាទៅនឹងអ្វី ដែលតម្រូវឲ្យសរសេរដូចការដាក់ពាក្យសុំដោយលាយលក្ខណ៍អក្សរដែរ។

ខ. របៀបនៃការដាក់ពាក្យសុំ

ជាធម្មតានៅពេលដែលមានការដាក់ពាក្យសុំទាមទារអាហារកាតព្វកិច្ចនៅតុលាការ ជាទូទៅពាក្យសុំនោះត្រូវ បញ្ជូនទៅកាន់មន្ត្រីទទួលបន្ទុកពាក្យបណ្ដឹងរដ្ឋប្បវេណី ជាអ្នកវាយត្រាលើពាក្យសុំដែលទទួលបាន ហើយចុះកាលបរិច្ឆេទនៃការទទួល និងចុះលេខរៀងនៅក្នុងសៀវភៅទទួលពាក្យបណ្ដឹង រួមទាំងចេញបង្កាន់ដៃបង់ប្រាក់ផងដែរ។ ប៉ុន្តែមុនពេលទទួលពាក្យសុំមកធ្វើចំណាត់ការដូចខាងលើ មន្ត្រីរដ្ឋបាលផ្នែកទទួលបន្ទុកពាក្យសុំគួរត្រួតពិនិត្យមើលពាក្យសុំមួយត្រួសជាមុនសិន ប្រសិនបើមានខ្វះខាតនៅត្រង់ចំណុចណាមួយនៃពាក្យសុំ គួរ

[30] មាត្រា២៦ កថាខណ្ឌទី២ ចំណុច ក នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

គប្បីពន្យល់ឲ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវលើចំណុចនោះជាមុនសិន។ បន្ទាប់ពីកែតម្រូវលើចំណុចដែលខ្វះខាតរួចមក មន្ត្រីរដ្ឋបាលត្រូវបញ្ជូន ទៅឲ្យប្រធានតុលាការ។

### ២.១.២ ការបង់ប្រាក់ប្រដាប់ក្តី

បន្ទាប់ពីពាក្យសុំត្រូវបានបំពេញរួចរាល់ អ្នកដាក់ពាក្យសុំត្រូវធ្វើការបង់នូវប្រាក់ប្រដាប់ក្តីជាមុនសិន ទើបពាក្យសុំនោះអាចដំណើរការបាន។ ការបង់ប្រាក់ប្រដាប់ក្តី គឺជាពន្ធសរុប និងចំណាយផ្សេងៗ ដែលត្រូវបង់សម្រាប់ដំណើរការនៃរឿងក្តីរដ្ឋប្បវេណី និងទទួលបន្ទុកដោយភាគីនៃរឿងក្តីផ្ទាល់។ ព្រោះតែតុលាការរដ្ឋប្បវេណី ជាតុលាការអកម្ម ហើយរឿងក្តីរដ្ឋប្បវេណី គឺជាការប្រើប្រាស់នូវប្រព័ន្ធតុលាការដើម្បីការពារនូវផលប្រយោជន៍របស់បុគ្គលឯកជនតែប៉ុណ្ណោះ។ ចំពោះការបង់ប្រាក់ប្រដាប់ក្តីដែលអ្នកដាក់ពាក្យសុំត្រូវបង់ មាន២ប្រភេទគឺ ពន្ធដាក់ពាក្យសុំ និងប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ។

ក. ពន្ធដាក់ពាក្យសុំ

ពន្ធដាក់ពាក្យសុំ គឺជាប្រាក់ពន្ធដែលដើមចោទត្រូវបង់នៅពេលដាក់ពាក្យបណ្តឹង ទៅតាមចំនួនដែលគណនាតាមតម្លៃកម្មវត្ថុនៃបណ្តឹង ហើយតម្លៃកម្មវត្ថុ នៃបណ្តឹងត្រូវបានគណនា ដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍ ដែលបានទាមទារក្នុងបណ្តឹងនោះ។[31]

ជាធម្មតានៅពេលដែលមានការដាក់ពាក្យសុំ ឬ ពាក្យបណ្តឹងទៅកាន់តុលាការដើម្បីទទួលបានការដោះស្រាយចំពោះបញ្ហាដែលកើតមានឡើង ចាំបាច់ឲ្យមានការបង់ពន្ធជាមុនសិន រួមទាំងពាក្យសុំទាមទារអាហារកាតព្វកិច្ចផងដែរ។

អ្នកដាក់ពាក្យសុំទាមទារអាហារកាតព្វកិច្ច ត្រូវបង់ពន្ធលើពាក្យសុំចំនួន ៥.០០០ (ប្រាំពាន់) រៀល។[32] ជាងនេះទៅទៀត តុលាការអាចធ្វើការកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឲ្យបង់ពន្ធប្រសិនបើអ្នកដាក់ពាក្យសុំមិនបានធ្វើការបង់ពន្ធ។[33] ប៉ុន្តែប្រសិនបើ អ្នកដាក់ពាក្យសុំនៅតែមិនព្រមបង់ពន្ធ តាមអំឡុងពេលដែលតុលាការបានកំណត់ទៀត នោះតុលាការអាចធ្វើការលើកចោលពាក្យសុំដោយដីកាសម្រេច[34]។

ខ. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

បន្ទាប់ពីពន្ធដាក់ពាក្យសុំ ដើមចោទក៏ត្រូវបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ។ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ជាពន្ធដែលភាគី ឬ បុគ្គលដែលពាក់ព័ន្ធនឹងរឿងក្តីត្រូវបង់ឲ្យតុលាការដោយចំនួនទឹកប្រាក់ដាក់លាក់ដែលកំណត់ដោយតុលាការ សម្រាប់ការចំណាយលើសកម្មភាពនីតិវិធីរបស់តុលាការ។ ដូចជា សម្រាប់ការត្រួត

[31] មាត្រា ៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[32] មាត្រា ២២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[33] មាត្រា ២២ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[34] មាត្រា ២២ កថាខណ្ឌទី៧ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

ពិនិត្យភស្តុតាង ការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងទៀត តាមនីតិវិធីនៅក្នុងបណ្តឹងរដ្ឋប្បវេណី។[35] លើសពីនេះទៅទៀត ជាសោហ៊ុយធ្វើដំណើរ ស្នាក់នៅសម្រាប់ចៅក្រម និងក្រឡាបញ្ជី ដើម្បីធ្វើការពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀតនៅខាងក្រៅតុលាការ។[36] ចំពោះប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធតុលាការត្រូវបង្គាប់ឲ្យភាគី ឬបុគ្គលដែលទាក់ទងរឿងក្តី បង់ចំនួនប្រាក់ជាមុនសិន។[37] ក្នុងករណីតុលាការបានបង្គាប់ឲ្យសាមីខ្លួនបង់ប្រាប់ប្រដាប់ក្តីជាមុន តែសាមីខ្លួនមិនបានបង់ជាមុនទេនោះ តុលាការអាចមិនធ្វើនូវសកម្មភាពដែលចាំបាច់ត្រូវមានប្រាក់ប្រដាប់ក្តីនោះបាន។

ចំពោះសោហ៊ុយធ្វើដំណើរសម្រាប់ចៅក្រម ដែលអ្នកដាក់ពាក្យសុំត្រូវបង់ មានចំនួន ៤៦.០០០រៀល និងសោហ៊ុយសម្រាប់ស្នាក់នៅរបស់ចៅក្រម មានចំនួន៨០.០០០រៀល។[38] ចំណែកឯ សោហ៊ុយធ្វើដំណើរសម្រាប់ក្រឡាបញ្ជី មានចំនួន២៣.០០០រៀល និងសោហ៊ុយសម្រាប់ស្នាក់នៅ ចំនួន៤០.០០០រៀល។[39] ប៉ុន្តែសោហ៊ុយស្នាក់នៅ អាចផ្តល់ជូន តែក្នុងករណីចម្ងាយធ្វើដំណើរលើសពី ៤០គីឡូម៉ែត្រប៉ុណ្ណោះ លើកលែងតែ ខេត្តរតនគីរីខេត្តមណ្ឌលគីរី ខេត្តព្រះវិហារ និងខេត្តបន្ទាយមានជ័យ ដែលសោហ៊ុយស្នាក់នៅអាចផ្តល់ជូន ក្នុងករណីដែលចម្ងាយធ្វើដំណើរលើសពី ៣០គីឡូម៉ែត្រ។ រីឯសោហ៊ុយសម្រាប់បញ្ជូនឯកសារតាមលិខិតអនុសិដ្ឋ គឺដូចគ្នាទៅនឹងថ្លៃចំណាយក្នុងការបញ្ជូនឯកសារជាសំបុត្រអនុសិដ្ឋ ដោយមានរបាយការណ៍បញ្ជាក់ពីការដល់នៃភណ្ឌិការ (កញ្ចប់ផ្ញើ តាមប្រៃសណីយ៍)។[40]

35 មាត្រា ៦២ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

36 មាត្រា ៦២ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

37 មាត្រា ៦២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

38 ឧបសម្ព័ន្ធ៣ ចំណុចទី១ និង ចំណុចទី៣ នៃប្រកាសស្តីពីការកែសម្រួល ឧបសម្ព័ន្ធ១ និង ឧបសម្ព័ន្ធ៤ នៃប្រកាសលេខ ២៨ កយ ប្រក,០៧ ស្តីពី ប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធ ចំនួនទឹកប្រាក់ នៃពន្ធ ដាក់ពាក្យសុំ និង ចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឲ្យតុលាការសម្រេចសេចក្តី និង មាត្រាដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្តី តុលាការក្រៅពីពន្ធ និង តម្លៃកម្មវត្ថុនៃបណ្តឹង

39 ឧបសម្ព័ន្ធ៣ ចំណុចទី២ និង ចំណុចទី៤ នៃប្រកាសស្តីពីការកែសម្រួល ឧបសម្ព័ន្ធ១ និង ឧបសម្ព័ន្ធ៤ នៃប្រកាសលេខ ២៨ កយ ប្រក,០៧ ស្តីពី ប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធ ចំនួនទឹកប្រាក់ នៃពន្ធ ដាក់ពាក្យសុំ និង ចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឲ្យតុលាការសម្រេចសេចក្តី និង មាត្រាដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្តី តុលាការក្រៅពីពន្ធ និង តម្លៃកម្មវត្ថុនៃបណ្តឹង

40 ឧបសម្ព័ន្ធ៣ ចំណុចទី៥ នៃប្រកាសស្តីពីការកែសម្រួល ឧបសម្ព័ន្ធ១ និង ឧបសម្ព័ន្ធ៤ នៃប្រកាសលេខ ២៨ កយ ប្រក,០៧ ស្តីពី ប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធ ចំនួនទឹកប្រាក់ នៃពន្ធ ដាក់ពាក្យសុំ និង ចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឲ្យតុលាការសម្រេចសេចក្តី និង មាត្រាដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្តី តុលាការក្រៅពីពន្ធ និង តម្លៃកម្មវត្ថុនៃបណ្តឹង

## ២.២ ដំណាក់កាលនៃការវិនិច្ឆ័យ និងសម្រេចសេចក្តី

ដំណាក់កាលនៃការវិនិច្ឆ័យ និងសម្រេចសេចក្តី ជាដំណាក់កាលបន្ទាប់ដែលតុលាការចាប់ផ្តើមដំណើរការលើពាក្យសុំទាមទារអាហារកាតព្វកិច្ច ក្រោយពីការដាក់ពាក្យសុំរបស់ភាគី។

### ២.២.១ ការវិនិច្ឆ័យ

ក. ការស្រាវជ្រាវ និង ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

ក្រោយពេលដែលពាក្យសុំទាមទារអាហារកាតព្វកិច្ច ត្រូវបានបំពេញគ្រប់លក្ខខណ្ឌ ហើយបុគ្គលដែលជាអ្នកដាក់ពាក្យសុំបានបង់ប្រាក់ប្រដាប់ក្តីរួចរាល់ សំណុំពាក្យសុំនឹងត្រូវបញ្ជូនទៅកាន់ចៅក្រម តាមរយៈរដ្ឋបាលនៃសាលាដំបូង ដែលអ្នកដាក់ពាក្យសុំបានដាក់ទាមទារអាហារកាតព្វកិច្ច។ បន្ទាប់មកប្រធានតុលាការ ចារឈ្មោះចៅក្រម ទទួលបន្ទុកតាមលំដាប់បន្ទាប់ដែលបានកំណត់ លើសាមីនៃពាក្យសុំនោះ ហើយមន្ត្រីរដ្ឋបាលនឹងយកពាក្យសុំនោះទៅឲ្យក្រឡាបញ្ជីរដ្ឋបាលនៃបន្ទាប់ចៅក្រមទទួលបន្ទុកនោះ។ បន្ទាប់មកក្រឡាបញ្ជីរដ្ឋបាលនោះ ត្រូវទទួលសាមីនៃពាក្យសុំនោះ ហើយយកទៅឲ្យចៅក្រមទទួលបន្ទុកនោះ។ ចៅក្រមនោះត្រូវចារឈ្មោះក្រឡាបញ្ជីណាជាអ្នកកាន់ពាក្យសុំនោះ លើសាមីនៃពាក្យសុំ។ ក្រោយមកក្រឡាបញ្ជីរដ្ឋបាលនោះ ត្រូវយកសាមីពាក្យសុំចុះក្នុងសៀវភៅទទួលពាក្យសុំរបស់ខ្លួន។

នៅពេលដែលសំណុំនៃពាក្យសុំបានទៅដល់ដៃរបស់ចៅក្រម ចៅក្រមនឹងធ្វើការត្រួតពិនិត្យទៅលើពាក្យសុំនោះ ថាពិតជាត្រឹមត្រូវដែលអាចធ្វើជាមូលដ្ឋានសម្រាប់ទាមទារបានឬទេ ប្រសិនបើចៅក្រមបានពិនិត្យមើលឃើញពីចំណុចខ្វះខាតណាមួយនៅក្នុងពាក្យសុំ នោះចៅក្រមអាចធ្វើការបញ្ជូនឲ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវលើចំណុចដែលខ្វះខាតបាន។

បន្ទាប់ពីពាក្យសុំទាមទារអាហារកាតព្វកិច្ចមានលក្ខណៈត្រឹមត្រូវ ហើយចំណុចដែលជាកម្មវត្ថុនៃការដាក់ពាក្យសុំក៏មានលក្ខណៈសមស្របតាមកំណត់របស់ច្បាប់ នោះចៅក្រម និងចាប់ផ្តើមធ្វើការស្រាវជ្រាវដោយការប្រើប្រាស់នូវឆន្ទានុសិទ្ធិ និង ការពិនិត្យទៅលើភស្តុតាងផងដែរ។ មានន័យថា ចៅក្រមអាចធ្វើការស្រាវជ្រាវទៅលើអង្គហេតុ ក៏ដូចជាកម្មវត្ថុនៃការដាក់ពាក្យសុំ របស់អ្នកដាក់ពាក្យដោយផ្អែកទៅលើភស្តុតាងដែលភ្ជាប់មកជាមួយនឹងពាក្យសុំ។

លើសពីនេះទៅទៀត តុលាការក៏អាចយកអង្គហេតុដែលមិនបានអះអាងដោយអ្នកដាក់ពាក្យសុំ ឬដោយភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបានដែរ ប្រសិនបើការអះអាងទាំងនោះអាចផ្តល់ភាពងាយស្រួល ឬមួយជាចំណុចសំខាន់ណាមួយដល់ការសម្រេចសេចក្តី។ តុលាការ ក៏អាចធ្វើការស្រាវជ្រាវអង្គហេតុ និង ធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ ប្រសិនបើយល់ឃើញថាចាំបាច់។[41]

[41] មាត្រា ២៧ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

ខ. នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់

ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្តី ដែលសកម្មភាពរបស់តុលាការ និង សកម្មភាពរបស់ភាគី ត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និង ការស្តាប់សេចក្តីថ្លែងការណ៍ នៅសាលសវនាការដែលបើកចំហជាសាធារណៈ។[42] តាមរយៈការទាញហេតុផលដោយផ្ទាល់មាត់នេះ ភាគីវិវាទត្រូវទទួលបាននូវសិទ្ធិបញ្ចេញមតិរបស់ខ្លួនអំពីចំណុច ដែលត្រូវវិនិច្ឆ័យដោយតុលាការនៅក្នុងបណ្តឹងនោះ ដើម្បីឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍របស់ភាគីម្ខាងទៀតមុនពេលតុលាការសម្រេចសេចក្តី។ លើសពីនេះទៅទៀត ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចមានវត្តមានបាន។[43] តុលាការអាចកោះហៅអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀត ដែលតុលាការយល់ឃើញថាចាំបាច់ ដោយកំណត់កាលបរិច្ឆេទ។[44] ប្រសិនបើជនដែលត្រូវបានកោះហៅដោយតុលាការមិនបានបង្ហាញខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល បាន។

ដោយឡែក តុលាការអាចចេញដីកាសម្រេច ដោយពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ។[45] ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់។[46] ការសួរនេះ ជាវិធីសាស្ត្រដែលតុលាការ អាចប្រមូលព័ត៌មានអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀត ដើម្បីជាមូលដ្ឋានក្នុងការសម្រេច។ ការសួរខាងលើ គ្មានទម្រង់បែបបទកំណត់ ហើយមិនចាំបាច់មានវត្តមានរបស់ភាគីទាំងសងខាងឡើយ។

លើសពីនេះទៅទៀត ប្រសិនបើតុលាការយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការអំពីរឿងក្តី និងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬក្នុងកាលបរិច្ឆេទនៃការសួរ។[47]

---

[42] មាត្រា ១១៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[43] មាត្រា ១១៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[44] មាត្រា ២៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[45] មាត្រា ២៨ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[46] មាត្រា ២៨ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[47] មាត្រា ៣០ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

គ. មូលដ្ឋានគណនាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច

កម្រិត និងរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវកំណត់តាមការពិភាក្សាគ្នា ព្រោះករណីខ្លះ ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច អាចរស់នៅជាមួយជនដែលមានករណីយកិច្ចបាន ករណីខ្លះទៀតជនទាំងនោះពុំអាចរស់នៅជាមួយគ្នាបានទេ តែជនដែលមានករណីយកិច្ច អាចផ្តល់ជាថវិកា ឬគ្រឿងឧបភោគបរិភោគ និងសម្លៀកបំពាក់ឱ្យទៅ ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចបាន។ មួយវិញទៀត បើការពិភាក្សាមិនបានសម្រេច ឬពុំអាចពិភាក្សាពីកម្រិត ឬរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ចបានទេ តុលាការត្រូវកំណត់ ដោយពិចារណាទៅលើសេចក្តីត្រូវការចាំបាច់ក្នុងជីវភាពរស់នៅ របស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច លទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ច និងស្ថានភាពផ្សេងទៀតទាំងអស់។[48] មានន័យថា តុលាការត្រូវពិចារណា ថាតើអាហារកាតព្វកិច្ចត្រូវផ្គត់ផ្គង់ត្រឹមកម្រិតណាមួយជាក់លាក់។ បើយោងលើក្រមរដ្ឋប្បវេណីបានអះអាងឱ្យជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ផ្គត់ផ្គង់ជីវភាពរស់នៅលើជនដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច ត្រឹមកម្រិតអប្បបរមាតែប៉ុណ្ណោះ ពុំមែនផ្គត់ផ្គង់ឱ្យស្មើទៅនឹងការទាមទាររបស់ជនដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ចនោះទេ។ ហើយកម្រិតអប្បបរមានោះ គឺអាស្រ័យទៅតាមស្ថានភាពជាក់ស្តែង ដែលជនមានសិទ្ធិទទួលបានអាហារកាតព្វកិច្ចនោះស្ថិតនៅតែប៉ុណ្ណោះ។

នៅក្នុងកំណត់នៃមាត្រា ១១៤២ បានធ្វើការបកស្រាយថា "ជាគោលការណ៍ របៀបផ្គត់ផ្គង់អាហារកាតព្វកិច្ច គឺជាការផ្តល់តាវកាលិកជាប្រាក់ ពីជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ទៅជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច។ ប៉ុន្តែ បន្ទាប់ពីមានការពិភាក្សារវាងភាគី ឬតាមសេចក្តីសម្រេចតុលាការរួចហើយ ប្រសិនបើអាចដោះស្រាយភាពចាំបាច់នៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច តាមរយៈការផ្តល់តាវកាលិកជាវត្ថុក្រៅពីប្រាក់បាន ការផ្តល់តាវកាលិកជាវត្ថុនោះ ក៏អាចធ្វើទៅបានដូចគ្នា។ ជាឧទាហរណ៍ ការផ្តល់តាវកាលិកជាវត្ថុនោះ អាចផ្តល់ជាអាហារ បរិក្ខារពេទ្យសម្រាប់ព្យាបាលជម្ងឺ ឬជាទីជម្រកសម្រាប់ជ្រកជាដើម។ ម្យ៉ាងវិញទៀត ក៏អាចមានករណីដែលជនមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ពុំមានប្រាក់គ្រប់គ្រាន់សម្រាប់ចំណាយលើអាហារកាតព្វកិច្ចទេ ប៉ុន្តែជននោះអាចមានបន្ទប់ទំនេរនៅក្នុងផ្ទះរបស់ខ្លួន ហើយអាចផ្តល់អាហារសម្រាប់បុគ្គលម្នាក់បានដូចគ្នា ហេតុដូច្នេះ ក៏អាចផ្តល់អាហារកាតព្វកិច្ចឱ្យជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច តាមរយៈការរស់នៅជាមួយជនដែលមានករណីយកិច្ចបានផងដែរ ហើយអាហារកាតព្វកិច្ចបែបនេះហៅថា ការផ្គត់ផ្គង់ដោយឱ្យរស់នៅជាមួយគ្នា។ ប៉ុន្តែ ទោះបីជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ស្នើសុំផ្តល់ការផ្គត់ផ្គង់ដោយឱ្យរស់នៅជាមួយគ្នា ក៏ដោយ ក៏អាចមានករណីដែលជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចអាចមិនយល់ព្រម ចំពោះសំណើនេះផងដែរ។ ផ្ទុយទៅវិញ ក៏អាចមានករណីផ្សេងទៀត ដែលជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ស្នើសុំ ការផ្គត់ផ្គង់ដោយឱ្យរស់នៅជាមួយគ្នា តែជនដែលមានករណីយកិច្ច បដិសេធការរស់នៅជាមួយគ្នានោះបានដែរ។ សរុបមក

[48] មាត្រា ១១៤២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ប្រសិនបើមានជនណាម្នាក់បានបដិសេធការរស់នៅជាមួយជនណាម្នាក់ទៀតហើយ នោះច្បាប់មិនអាចបង្ខំឱ្យជនទាំងនោះរស់នៅជាមួយគ្នាបានទេ។"

ក្រោយពីបានកំណត់ពីបុគ្គលដែលមានករណីយកិច្ច ក្នុងការផ្គត់ផ្គង់អាហារកាតព្វកិច្ចរួចមក តុលាការចាំបាច់ត្រូវធ្វើការកំណត់ចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ចប្រចាំខែ ឬ ប្រចាំឆ្នាំ ដោយការពិចារណាអំពីស្ថានភាពជីវភាពរបស់អ្នកមានករណីយកិច្ចទទួលបន្ទុកអាហារកាតព្វកិច្ច ក្រោយពីការចំណាយលើការផ្គត់ផ្គង់នានានៅក្នុងគ្រួសារ ដើម្បីផ្ដល់ជាភាពងាយស្រួលដល់មូលដ្ឋានក្នុងការគណនាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច។

ដើម្បីធ្វើការគណនាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច ត្រូវធ្វើការគណនារក សោហ៊ុយសម្រាប់ជីវភាពអប្បបរមា របស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច និងកម្មវត្ថុនៃអាហារកាតព្វកិច្ចជាមុនសិន។ ដោយសោហ៊ុយសម្រាប់ជីវភាពអប្បបរមារបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច គឺរួមបញ្ចូលទាំងថ្លៃស្នាក់នៅ អាហារបីពេល សម្លៀកបំពាក់ ថ្លៃសេវាសុខភាព និងថ្លៃចំណាយផ្សេងៗទៀត។ សោហ៊ុយសម្រាប់ជីវភាពអប្បបរមារបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ត្រូវយកថ្លៃចំណាយរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ដក ប្រាក់ចំណូលរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ប្រសិនបើអ្នកមានសិទ្ធិទាមទារមានប្រាក់ចំណូល។ ចំណែកឯ កម្មវត្ថុនៃអាហារកាតព្វកិច្ច គឺជាចំនួនទឹកប្រាក់ដែលនៅសេសសល់បន្ទាប់ពីការចាត់ចែងក្នុងការផ្គត់ផ្គង់ក្នុងគ្រួសារ សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់អ្នកមានករណីយកិច្ច។ ចំពោះកម្មវត្ថុនៃអាហារកាតព្វកិច្ច ត្រូវយកចំណូលសរុបរបស់ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ដក សោហ៊ុយក្នុងការចំណាយរបស់ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច លើការរស់នៅ។ ក្រោយពីការគណនារកឃើញ សោហ៊ុយសម្រាប់ជីវភាពអប្បបរមារបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច និង កម្មវត្ថុនៃអាហារកាតព្វកិច្ច យើងនឹងត្រូវធ្វើការប្រៀបធៀបអំពីចំនួនទឹកប្រាក់មួយណាដែលមានចំនួនតិចជាង ចំនួនដែលតិចជាងនឹងក្លាយទៅជាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច។ ចំពោះរូបមន្ត ជាមូលដ្ឋានក្នុងការគណនាចំនួនអាហារកាតព្វកិច្ច មានក្នុងឧបសម្ព័ន្ធទី២។

ឧបមាថា៖ សុខា មានប្រាក់ចំណូលប្រចាំខែត្រឹមតែ ១៥០ដុល្លា ដោយសារតែការចំណាយជាប្រចាំលើការរស់នៅរបស់ខ្លួនត្រូវចំណាយរហូតដល់ទៅ ២៥០ដុល្លា ក្នុងមួយខែ។ សុវណ្ណ ជាបងប្រុស ហើយក៏ជាអ្នកមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច។ ដោយ សុវណ្ណ មានប្រាក់ចំណូល ៧៥០ដុល្លា ក្នុងមួយខែ ហើយត្រូវចំណាយ ៦០០ដុល្លា ក្នុងការរស់នៅជាប្រចាំ។ ក្រោយពីការចំណាយក្នុងជីវភាពរស់នៅ សុវណ្ណ នៅសល់ប្រាក់១៥០ដុល្លា ដែលជាកម្មវត្ថុនៃអាហារកាតព្វកិច្ច។ អាស្រ័យហេតុដូច្នេះ សុវណ្ណ ត្រូវផ្ដល់ប្រាក់ ១០០ដុល្លា ក្នុងមួយខែ ទៅឲ្យសុខា ដែលជាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច។

### ២.២.២ ការសម្រេចសេចក្តី

ក. វិធីសម្រេចសេចក្តី

ចំពោះវិធីសម្រេចសេចក្តី គឺចៅក្រម ឬតុលាការសម្រេចតាមរយៈដីកាសម្រេច ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ក៏បាន។[49] មួយវិញទៀត នៅកម្ពុជាសព្វថ្ងៃពុំទាន់មានវិធីសម្រេចសេចក្តីទាក់ទងនឹងអាហារកាតព្វកិច្ចនៅឡើយទេ។ គ្រាន់តែជាទូទៅ ចៅក្រមពិនិត្យមើល ពាក្យសុំរួចហើយហៅភាគីទាំងសងខាងមក ដើម្បីធ្វើនីតិវិធីសាកសួរចំពោះភាគី ជាការសាកសួរជាក់ស្តែងទៅលើភាគី និងត្រួតពិនិត្យទៅលើស្ថានភាពរបស់ភាគី ថាតើអាចមានលទ្ធភាពក្នុងការផ្តត់ផ្គង់អាហារកាតព្វកិច្ចដល់ជនដែលមានសិទ្ធិទាមទារអាហារកាតព្វកិច្ចដែរ ឬទេ។ បន្ទាប់ពីសាកសួរភាគីរួចរាល់ ចៅក្រមធ្វើការសម្រេចសេចក្តីដោយផ្អែកលើប្រាក់ចំណូល និងប្រាក់ចំណាយប្រចាំខែជាក់ស្តែង របស់ជនដែលមានករណីយកិច្ច ដោយធ្វើការថ្លឹងថ្លែង ថាតើគួរឱ្យជននោះផ្តល់អាហារកាតព្វកិច្ចនៅកម្រិតណាមួយ។ ក្រោយពីចៅក្រមធ្វើការសម្រេចសេចក្តីរួចរាល់ ដោយដីកាបង្គាប់ឲ្យផ្តល់អាហារកាតព្វកិច្ច ដូច្នេះអ្នកមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចត្រូវអនុវត្តតាមការកំណត់របស់ដីកានោះ។

ជាគោលការណ៍ ដីកាសម្រេចបង្គាប់ឱ្យផ្តល់អាហារកាតព្វកិច្ច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេច។[50] ការសរសេរសំអាងហេតុ គឺដើម្បីធានាភាពមិនលំអៀងក្នុងការវិនិច្ឆ័យរបស់ចៅក្រម ព្រមទាំងដើម្បីបង្ហាញឱ្យបានច្បាស់លាស់នូវមូលហេតុនៃការវិនិច្ឆ័យចំពោះភាគី ដើម្បីឱ្យភាគីមានភាពងាយស្រួលក្នុងការប្តឹងជំទាស់។

ខ. ការជូនដំណឹងអំពីដីកាសម្រេច

បន្ទាប់ពីតុលាការសម្រេចសេចក្តីបង្គាប់ឱ្យផ្តល់អាហារកាតព្វកិច្ចរួចហើយ ជំហានបន្ទាប់ត្រូវជូនដំណឹងទៅជនដែលត្រូវទទួលដីកាសម្រេច ពោលគឺ ភាគីទាំងសងខាង។[51] ដីកាសម្រេចនឹងមានអានុភាព លុះត្រាតែត្រូវបានជូនដំណឹងតាមវិធីដែលអាចទទួលស្គាល់ថាសមរម្យ។[52] ការជូនដំណឹងអំពីដីកាសម្រេច ត្រូវធ្វើឡើងតាមរយៈការបញ្ជូន ឬការផ្ញើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេច។[53] លើសពីនេះទៅទៀត ការបញ្ជូន ត្រូវប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី។[54] ចំពោះស្ថាប័នដែលត្រូវទទួលបន្ទុកនូវការប្រតិបត្តិកិច្ចការបញ្ជូន ត្រូវពិចារណាតាមស្ថានភាពនៃការរៀបចំ និងការប្រព្រឹត្តនៃប្រព័ន្ធប្រៃសណីយ៍ និង

[49] មាត្រា ១៧៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[50] មាត្រា ៣៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[51] មាត្រា ៣៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[52] មាត្រា ២១៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[53] មាត្រា ៣៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[54] មាត្រា ២៤៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ស្ថានភាពនៃការរៀបចំប្រព័ន្ធអាជ្ញាសាលាជាអាទិ៍។ ក្នុងករណីចេញដីកាសម្រេចជាលាយល័ក្ខណ៍អក្សរ ចៅក្រមដែលបានចេញដីកាសម្រេច ត្រូវចុះហត្ថលេខាលើដីកាសម្រេចនោះ។[55] នៅពេលជូនដំណឹងអំពីដីកាសម្រេច ក្រឡាបញ្ជីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវហេតុការណ៍ និងវិធីនៃការជូនដំណឹងនោះ ដាក់នៅក្នុងសំណុំរឿង។[56]

គ. ការចូលជាស្ថាពរ និងការបង្កើតអានុភាពនៃការសម្រេច

ដីកាសម្រេចបង្គាប់ឱ្យផ្តល់អាហារកាតព្វកិច្ច ចូលជាស្ថាពរនៅអំឡុងពេលសម្រាប់ប្តឹងជំទាស់ បានកន្លងហួស ឬពេលដែលពាក្យបណ្តឹងជំទាស់ ត្រូវបានលើកចោលដោយតុលាការនៃបណ្តឹងជំទាស់។[57] មួយវិញទៀត ការប្តឹងជំទាស់ ត្រូវធ្វើឡើងក្នុងអំឡុងពេល ពីរសប្តាហ៍ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេច។[58] អំឡុងពេលនេះមិនអាចពន្យារបាននោះទេ។[59] ផ្ទុយទៅវិញ ប្រសិនបើគ្មានការប្តឹងជំទាស់ទេនោះ ដីកាសម្រេចបង្គាប់ឱ្យផ្តល់អាហារកាតព្វកិច្ចនឹងចូលជាស្ថាពរ។

ប្រសិនបើមានបណ្តឹងជំទាស់ ដីកាសម្រេចដើមនេះក៏មិនមានអានុភាពដែរ នាំឱ្យមិនទាន់ចូលជាស្ថាពរ ដោយហេតុថា ត្រូវបានបង្អាក់ដោយការប្តឹងជំទាស់។[60] មានន័យថា ប្រសិនណា មានបណ្តឹងជំទាស់កើតមានឡើងរវាងភាគីម្ខាងទៀត ទៅតុលាការជាន់ខ្ពស់នោះ ដីកាសម្រេចដើមពុំទាន់មានអានុភាពទេ។ ព្រោះបុគ្គលទទួលឥទ្ធិពលដែលខូចប្រយោជន៍ដល់សិទ្ធិ ឬឋានៈគតិយុត្តរបស់ខ្លួនដោយសារដីកាសម្រេច អាចប្តឹងជំទាស់ចំពោះដីកាសម្រេចនោះបាន។[61]

ម្យ៉ាងវិញទៀត ប្រសិនបើអ្នកដាក់ពាក្យសុំទាមទារអាហារកាតព្វកិច្ចផ្ទាល់ បានទាមទារច្រើនចំណុចនៅក្នុងពាក្យសុំ ហើយត្រូវបានតុលាការលើកចោលត្រង់ចំណុចណាមួយក្នុងដីកាសម្រេច នោះមានតែជនដែលបានដាក់ពាក្យសុំប៉ុណ្ណោះ ដែលអាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំនេះបាន។[62]

ដើម្បីធ្វើបណ្តឹងជំទាស់ ភាគីត្រូវដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការដើម។[63] នៅក្នុងបណ្តឹងជំទាស់ គួរតែចុះអំពីមូលហេតុច្បាស់លាស់នៃការសុំលុបចោល ឬផ្លាស់ប្តូរដីកាសម្រេចដើម ក៏ប៉ុន្តែ ប្រសិនបើមិនសរសេរពីមូលហេតុទាំងនោះ ក៏បណ្តឹងជំទាស់នោះប្រែជាគ្មានសុពលភាពនោះដែរ។ ក្នុងករណីដែលពាក្យបណ្តឹងជំទាស់

[55] មាត្រា ២១៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[56] មាត្រា ២១៣ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[57] មាត្រា ៣៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[58] មាត្រា ៤០ កថាខណ្ឌទី១ និងកថាខណ្ឌទី៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[59] មាត្រា ៤០ កថាខណ្ឌទី១ និងកថាខណ្ឌទី៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[60] មាត្រា ៣៧ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[61] មាត្រា ៣៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[62] មាត្រា ៣៩ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[63] មាត្រា ៣០១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

មិនបានសរសេរអំពីមូលហេតុនោះទេ ដើមបណ្ដឹងជំទាស់គប្បីដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងជំទាស់នោះ ទៅតុលាការនៃបណ្ដឹងជំទាស់ ក្នុងអំឡុងពេល ពីរសប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្ដឹងជំទាស់នោះ។[64]

មួយវិញទៀត នៅពេលតុលាការជាន់ខ្ពស់ទទួលបានបណ្ដឹងជំទាស់ហើយ នឹងបន្តនីតិវិធីសាកសួរភាគីសាជាថ្មី។ សាលាឧទ្ធរណ៍ នឹងសម្រេចសេចក្ដីម្ដងទៀត ថាគួរលើកចោលបណ្ដឹងជំទាស់ ឬយ៉ាងណា។ ដោយការសម្រេចសេចក្ដីលើបណ្ដឹងជំទាស់ អាចធ្វើបាន ដោយមិនបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ទេ។[65] ក្នុងករណីដែលតុលាការនៃបណ្ដឹងជំទាស់ មិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់អំពីបណ្ដឹងជំទាស់ទេ តុលាការអាចធ្វើការសួរម្ចាស់បណ្ដឹងជំទាស់ ឬអ្នកផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍នៃបណ្ដឹងបាន។[66]

ឃ. អានុភាពនៃការអនុវត្តសេចក្ដីសម្រេច

ការអនុវត្តសេចក្ដីសម្រេច មានអានុភាពចងកាតព្វកិច្ច ដោយឱ្យបុគ្គលដែលមានករណីយកិច្ចទទួលបន្ទុកអនុវត្តកាតព្វកិច្ច ដូចដែលមានចែងក្នុងដីកាសម្រេច។ ម្យ៉ាងវិញទៀត ប្រសិនបើ បុគ្គលនោះ ពុំអនុវត្តតាមដីកាសម្រេច តុលាការអាចអនុវត្តដោយបង្ខំតាមពាក្យសុំរបស់ភាគី ដោយបង្គាប់ឱ្យអ្នកមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ផ្ដល់តាវកាលិកដែលមានកំណត់នៅក្នុងដីកាសម្រេចនោះតាមរយៈលិខិតអនុវត្ត។[67]

## ២.៣ ដំណាក់កាលនៃការផ្ដល់អាហារកាតព្វកិច្ច និងទណ្ឌកម្ម

ដំណាក់កាលនៃការផ្ដល់អាហារកាតព្វកិច្ច និងទណ្ឌកម្ម គឺជាដំណាក់កាលចុងក្រោយបន្ទាប់ពីដីកាសម្រេចបានចូលជាស្ថាពរ។

### ២.៣.១ កម្រិតនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច

ក. ការផ្គត់ផ្គង់ ការផ្លាស់ប្ដូរ ឬការលុបចោល និងអនុប្បទានអាហារកាតព្វកិច្ច

ក្រោយដីកាសម្រេចបង្គាប់ឲ្យផ្ដល់អាហារកាតព្វកិច្ចចូលជាស្ថាពរ ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវផ្ដល់អាហារកាតព្វកិច្ចលើជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច តាមខ្លឹមសារនៃដីកាសម្រេចបង្គាប់ឱ្យផ្ដល់អាហារកាតព្វកិច្ច។

[64] មាត្រា ៣០១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[65] មាត្រា ៣០៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[66] មាត្រា ៣០៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[67] មាត្រា ៣៨ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង និង មាត្រា ៣៥០ កថាខណ្ឌទី២ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី

រីឯការកំណត់កម្រិត និងរបៀបនៃការផ្តត់ផ្គង់អាហារកាតព្វកិច្ច អាចត្រូវបានផ្លាស់ប្តូរ ឬលុបចោលដោយការពិភាក្សា ឬតាមសេចក្តីសម្រេចរបស់តុលាការ ដោយពិចារណាលើការផ្លាស់ប្តូរស្ថានភាពរបស់ភាគី។[68] មានន័យថា ទំនាក់ទំនងនៃអាហារកាតព្វកិច្ចអាចនឹងត្រូវបានផ្លាស់ប្តូរ ឬលុបចោលទៅវិញ ទោះបីជាទំនាក់ទំនងនៃអាហារកាតព្វកិច្ច ត្រូវបានកំណត់តាំងពីដំបូង តាមរយៈការពិភាក្សា ឬតាមរយៈសេចក្តីសម្រេចតុលាការហើយក៏ដោយ ក៏ភាគីអាចធ្វើការផ្លាស់ប្តូរខ្លឹមសារដែលបានសម្រេចតាំងពីដំបូងនោះ តាមការពិភាក្សាបានដែរ។ ឧបមាថា ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច មានសមត្ថភាពចិញ្ចឹមជីវិតខ្លួនឯងសាជាថ្មីបាន ឬជនមានករណីយកិច្ចផ្តត់ផ្គង់ជួបប្រទះបញ្ហាហិរញ្ញវត្ថុ ដោយមិនអាចធ្វើការផ្តត់ផ្គង់អាហារកាតព្វកិច្ច ក្នុងកម្រិតណាមួយដូចមុនជាដើម។ នោះភាគីទាំងសងខាង អាចធ្វើការពិភាក្សាគ្នា អំពីការផ្លាស់ប្តូរ ឬលុបចោលអាហារកាតព្វកិច្ចនេះបាន។

ម្យ៉ាងវិញទៀត ប្រសិនបើការពិភាក្សា នៅតែពុំបានសម្រេច ឬពុំអាចពិភាក្សាបាន ភាគីអាចទាមទារទៅតុលាការឱ្យលុបចោល ឬផ្លាស់ប្តូរការពិភាក្សា ឬសេចក្តីសម្រេចតុលាការដែលបានធ្វើពីមុននោះបាន។[69] លើសពីនេះទៅទៀត ចំពោះការកំណត់ជាក់លាក់អំពីជនដែលត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ច និងជនដែលទទួលអាហារកាតព្វកិច្ច ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតុលាការ បង្គាប់ឱ្យលុបចោល ឬផ្លាស់ប្តូរកិច្ចព្រមព្រៀង ឬសេចក្តីសម្រេចតុលាការដែលបានធ្វើពីមុន។[70] ចំណែកឯសិទ្ធិទាមទារអាហារកាតព្វកិច្ច ត្រូវបានហាមឃាត់ដោយច្បាប់មិនឱ្យមានការចាត់ចែងបានឡើយ ដោយហេតុថាសិទ្ធិនេះ គឺជាសិទ្ធិផ្តាច់មុខរបស់បុគ្គលត្រូវការចាំបាច់នូវអាហារកាព្វកិច្ច ដែលពុំអាចយកមកធ្វើជាកម្មវត្ថុនៃអនុប្បទាន ប្រទានកម្ម ឬ ការបង្កើតសិទ្ធិប្រាតិភោគសម្រាប់តតិយជន ឬជំនួញផ្សេងៗទៀតបានឡើយ។[71]

នៅក្នុងកំណត់នៃមាត្រា ១១៤២ បានធ្វើការបកស្រាយថា "ជាគោលការណ៍ អាហារកាតព្វកិច្ចត្រូវបានផ្តល់តាមរយៈការបង់ប្រាក់ទៅជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ដោយជនដែលមានករណីយកិច្ចត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ច។ បើតាមទស្សនៈមួយនេះ សិទ្ធិទាមទារអាហារកាតព្វកិច្ច មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ចំពោះជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចមានចំពោះជនដែលមានករណីយកិច្ចត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ច។ ក៏ប៉ុន្តែ សិទ្ធិទទួលអាហារកាតព្វកិច្ច និងកាតព្វកិច្ចផ្តត់ផ្គង់អាហារកាតព្វកិច្ច មិនមែនកើតចេញពីកិច្ចសន្យាទេ ពោលគឺកើតចេញពីទំនាក់ទំនងជាក់លាក់មួយរវាងញាតិ។ អាស្រ័យហេតុនេះ ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច មិនអាចធ្វើអនុប្បទានសិទ្ធិទទួលអាហារកាតព្វកិច្ច

[68] មាត្រា ១១៤៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[69] មាត្រា ១១៤៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[70] មាត្រា ១១៤៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[71] មាត្រា ១១៤៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

នោះទៅតតិយជន ឬបង្កើតសិទ្ធិលើការបញ្ចាំសិទ្ធិទទួលអាហារកាតព្វកិច្ចនោះ ដើម្បីខ្ចីប្រាក់ពីអ្នកករកស៊ីចងការប្រាក់ដូចសិទ្ធិលើបំណុលដែរនោះបានទេ។ ដោយហេតុថា អាហារកាតព្វកិច្ច គឺជាជំនួយសម្រាប់តែជនក្រីក្រប៉ុណ្ណោះ អាហារកាតព្វកិច្ចបែបនេះ មិនគួរអាចត្រូវបានប្រើសម្រាប់គោលបំណងផ្សេងទៀតបានឡើយ។"

ខ. ការបញ្ចប់ការផ្តត់ផ្គង់អាហារកាតព្វកិច្ច

ជាធម្មតា អាហារកាតព្វកិច្ច ត្រូវបានផ្តត់ផ្គង់តែក្នុងកម្រិតអប្បបរមា និងក្នុងរយៈពេលកំណត់ជាក់លាក់ តាមការពិភាក្សា និងតាមដីកាសម្រេចណាមួយតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយ អាហារកាតព្វកិច្ច ក៏អាចនឹងបញ្ចប់ក្នុងរយៈពេលណាមួយផងដែរ ដែលការបញ្ចប់នេះអាចធ្វើតាមការពិភាក្សា និងការព្រមព្រៀងរវាងភាគីបាន។ ជាងនេះទៅទៀត ការបញ្ចប់ការផ្តត់ផ្គង់អាហារកាតព្វកិច្ច ក៏អាចបញ្ចប់តាមការលុបចោលរបស់តុលាការ ដោយមូលហេតុផ្លាស់ប្តូរស្ថានភាពរបស់ភាគីណាមួយផងដែរ។[72]

ក្រៅពីនេះ អាហារកាតព្វកិច្ចនឹងបញ្ចប់ នៅពេលដែលជនមានសិទ្ធិទាមទារអាហារកាតព្វកិច្ច បានទទួលមរណភាព ពីព្រោះសិទ្ធិទាមទារអាហារកាតព្វកិច្ចត្រូវបានរលត់ ដោយហេតុថាសិទ្ធិនេះជាសិទ្ធិផ្តាច់មុខ[73] ភ្ជាប់ជាមួយនឹងជនមានសិទ្ធិទទួលអាហារកាតព្វកិច្ច។ ម៉្យាងវិញទៀត ក្នុងករណីជនមានករណីយកិច្ចផ្តត់ផ្គង់អាហារកាតព្វកិច្ចបានទទួលមរណភាពវិញ នោះតុលាការត្រូវកំណត់រកអ្នកមានករណីយកិច្ចផ្តត់ផ្គង់អាហារកាតព្វកិច្ចបន្តទៀត ដោយយោងតាម ការកំណត់ជាក់លាក់ អំពីជនដែលត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ច និងជនដែលទទួលអាហារកាតព្វកិច្ច[74]។ រីឯសន្តតិជនរបស់មតកជន ដែលធ្លាប់ជាជនមានករណីយកិច្ចផ្តត់ផ្គង់អាហារកាតព្វកិច្ចវិញ មិនត្រូវបន្តនូវកាតព្វកិច្ចផ្តល់អាហារកាតព្វកិច្ចឡើយ។[75]

### ២.៣.២ ទណ្ឌកម្មនៃការមិនផ្តត់ផ្គង់អាហារកាតព្វកិច្ច

ក្នុងករណីដែលតុលាការបានចេញដីកាសម្រេចបង្គាប់ឲ្យផ្តល់អាហារកាតព្វកិច្ច និងបានកំណត់នូវកម្មវត្ថុរួចរាល់ហើយ ប៉ុន្តែជនមានករណីយកិច្ចមិនព្រមអនុវត្តនូវកាតព្វកិច្ចតាមដីកាសម្រេច បុគ្គលនោះនិងត្រូវទទួលទណ្ឌកម្មនៃការមិនផ្តត់ផ្គង់អាហារកាតព្វកិច្ច អាចកើតមានឡើងពីរករណី គឺ ការបង្ខំដោយអំណាចតុលាការឱ្យផ្តត់ផ្គង់កាតព្វកិច្ច និង ការទទួលខុសត្រូវព្រហ្មទណ្ឌ។

[72] មាត្រា ១១៤៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[73] មាត្រា ១១៤៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[74] មាត្រា ១១៤១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[75] មាត្រា១១៤៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ក. ការបង្ខំដោយអំណាចតុលាការឱ្យផ្តត់ផ្គង់កាតព្វកិច្ច

មុនឈានដល់ការចេញដីកាសម្រេចបង្គាប់ឲ្យផ្តល់អាហារកាតព្វកិច្ច ពិតណាស់ចៅក្រម គឺបានធ្វើការកំណត់ចំពោះជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច[76] និងកម្រិតនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច[77]។ ការដែលកំណត់នូវបុគ្គលជាក់លាក់ ដោយដីកាសម្រេចបង្គាប់ឲ្យផ្តល់អាហារកាតព្វកិច្ចនោះហើយ ដែលជាការបង្ខំដោយអំណាចតុលាការ ឲ្យជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវតែអនុវត្តនូវកាតព្វកិច្ច និង កម្មវត្ថុតាមការកំណត់។ ចំពោះការបង្ខំដោយអំណាចតុលាការឲ្យផ្គត់ផ្គង់ត្រូវធ្វើឡើង តាមរយៈការអនុវត្តដោយបង្ខំ ដែលជានីតិវិធីតាមផ្លូវតុលាការ ក្នុងការសម្រេចទាមទារ ឬសិទ្ធិប្រាតិភោគ ដោយប្រើអំណាចរបស់រដ្ឋក្នុងគោលដៅការពារសិទ្ធិរបស់បុគ្គលតាមផ្លូវច្បាប់ឯកជន។ នីតិវិធីអនុវត្តដោយបង្ខំត្រូវចាប់ផ្តើមដោយការដាក់ពាក្យសុំទៅតុលាការអនុវត្ត ឬអាជ្ញាសាលានៃទីតាំងការអនុវត្ត។

ចំពោះពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ។[78] ហើយមានបញ្ជាក់ ឈ្មោះ អាសយដ្ឋាន របស់ភាគីទាំងសងខាង ឬឈ្មោះ អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់កំណត់ សញ្ញាណនៃលិខិតអនុវត្ត សេចក្តីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំជាអាទិ៍ ដោយភ្ជាប់មកជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត។[79] ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើង ដោយផ្អែកលើលិខិតអនុវត្ត[80] ដោយលិខិតអនុវត្ត គឺជាលិខិតដីកាសម្រេចបង្ខំឲ្យផ្តល់តាវកាលិក[81]។

ខ. ការទទួលខុសត្រូវព្រហ្មទណ្ឌ

ប្រសិនបើ អ្នកមានករណីយកិច្ចមិនគោរពតាមសេចក្តីសម្រេចស្ថាពររបស់តុលាការ ដោយមិនព្រមបង់ក្នុងរយៈពេល ២ (ពីរ) ខែ យ៉ាងតិច នូវអាហារកាតព្វកិច្ចដល់សហព័ទ្ធ ឬ អតីតសហព័ទ្ធរបស់ខ្លួនដល់កូនជាអនីតិជន ដល់បច្ឆាញាតិ ឬ បុព្វញាតិ ឬ ដល់ញាតិផ្សេងទៀតរបស់ខ្លួននោះនឹងត្រូវជាប់ចោទពី បទបោះបង់គ្រួសារ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល។[82] ក្រៅពីការប្រកាសមូលទោស តុលាការក៏អាចធ្វើការ

[76] មាត្រា ១១៤១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[77] មាត្រា ១១៤២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[78] មាត្រា ៣៤៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[79] មាត្រា ៣៤៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[80] មាត្រា ៣៥០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[81] មាត្រា ៣៥០ កថាខណ្ឌទី២ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[82] មាត្រា ៣២៤ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ប្រកាសនូវទោសបន្ថែមលើជននោះបាន ដូចជា ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន និង ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន។[83]

[83] មាត្រា ៣២៥ ចំណុចទី១ និង ចំណុចទី២ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីឆ្លងកាត់ការសិក្សាស្រាវជ្រាវ និងបកស្រាយលើប្រធានបទ **អាហារកាតព្វកិច្ចតាមផ្លូវតុលាការ**។ យើងខ្ញុំសង្កេតឃើញថា ប្រធានបទនេះពិតជាមានសារៈសំខាន់ណាស់ ចំពោះស្ថានភាពជាក់ស្ដែងដែលតែងតែកើតមានឡើងក្នុងសង្គមនាពេលបច្ចុប្បន្ន នៅពេលដែលស្ថិតក្នុងស្ថានភាពលំបាកដែលមានដូចជាឪពុកម្ដាយដែលត្រូវបានកូនបោះបង់ចោលមិនយកចិត្តទុកដាក់នៅក្នុងការផ្គត់ផ្គង់មើលថែរក្សា កូនដែលមិនទទួលបានការចិញ្ចឹមបីបាច់ថែរក្សាពីឪពុកម្ដាយ និងបងប្អូនដែលមានលទ្ធភាពមិនព្រមជួយយកអាសារបងប្អូនដែលកំពុងខ្វះខាតក្នុងជីវភាពរស់នៅប្រចាំថ្ងៃឲ្យមានជីវភាពរស់នៅសមរម្យមួយ អាចទទួលបានការជួយសង្គ្រោះពីញាតិរបស់ខ្លួនបាន ឬអាចទទួលបានអាហារកាតព្វកិច្ចពីញាតិដែលរស់នៅជាមួយគ្នា ញាតិលោហិតខ្សែផ្ទាល់ បងប្អូនបង្កើត និងញាតិក្នុងថ្នាក់ទីបី ជាអាទិ៍។ ដោយអាហារកាតព្វកិច្ចនេះ អាចទទួលបានតាមរយៈការពិភាក្សាគ្នា រវាងញាតិដែលពាក់ព័ន្ធ ឬបើពិភាក្សាមិនបានសម្រេច នោះបុគ្គលដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច អាចធ្វើការដាក់ពាក្យសុំទៅតុលាការបាន ដើម្បីឱ្យតុលាការពិចារណាទៅលើសេចក្ដីត្រូវការចាំបាច់ ក្នុងជីវភាពរស់នៅរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច លទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ច និងស្ថានភាពផ្សេងៗទៀតទាំងអស់។

មួយវិញទៀត ចំពោះការដាក់ពាក្យសុំទាមទារអាហារកាតព្វកិច្ចទៅតុលាការ អ្នកដាក់ពាក្យសុំត្រូវធ្វើឡើងដោយការបំពេញពាក្យសុំ ភ្ជាប់ជាមួយភស្តុតាង និងត្រូវបង់ប្រាក់ប្រដាប់ក្ដីជាមុនសិនទើបពាក្យសុំនោះនិងចាប់ផ្ដើមនីតិវិធីបន្ត។ បន្ទាប់មកតុលាការ នឹងពិនិត្យលើពាក្យសុំ ហើយបន្តនីតិវិធីនៃការវិនិច្ឆ័យ និងសម្រេចសេចក្ដី។ ក្រោយពីដីកាសម្រេច ចូលជាស្ថាពរ ជនដែលមានករណីយកិច្ច ត្រូវទទួលបន្ទុកអនុវត្តកាតព្វកិច្ច ដូចដែលមានកំណត់ក្នុងដីកាសម្រេចនោះ។ ក្នុងករណីបុគ្គលដែលមានករណីយកិច្ចផ្គត់ផ្គង់ មិនព្រមផ្គត់ផ្គង់អាហារកាតព្វកិច្ចស្របតាមដីកាសម្រេចនោះទេ នឹងត្រូវទទួលទណ្ឌកម្ម ដោយការបង្ខំពីតុលាការ និង ការទទួលខុសត្រូវព្រហ្មទណ្ឌជាអាទិ៍។

សរុបជារួមមក យើងអាចធ្វើការសន្និដ្ឋានបានថា អាហារកាតព្វកិច្ចតាមផ្លូវតុលាការ ពិតជាបានជួយសង្គ្រោះ និងធានានូវការរស់នៅ ហើយផ្ដល់នូវសិទ្ធិឲ្យបុគ្គលដែលខ្វះសមត្ថភាពនៅក្នុងការប្រកបរបរចិញ្ចឹមជីវិតអាចធ្វើការទាមទារអាហារកាតព្វកិច្ចពីជនដែលមានករណីយកិច្ច ដោយមិនចាំបាច់ព្រួយបារម្ភថា គ្មានអ្នកណាអាចជួយសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន នៅពេលដែលខ្លួនកំពុងស្ថិតក្នុងស្ថានភាពលំបាកនោះទេ។ តួយ៉ាង អាហារកាតព្វកិច្ច ពិតជាមានសារៈសំខាន់ណាស់ចំពោះជនដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច នៅក្នុងករណីប្រសិនបើ អាហារកាតព្វកិច្ចតាមផ្លូវច្បាប់ អាហារកាតព្វកិច្ចតាមការព្រមព្រៀង និងអាហារកាតព្វកិច្ចតាមទំនៀមទម្លាប់ មិនអាចកើតមានឡើង។ ដោយសារតែអាហារកាតព្វកិច្ចតាមផ្លូវតុលាការ

ជាប្រភេទអាហារកាតព្វកិច្ចដែលត្រូវបានវិនិច្ឆ័យ និងសម្រេចសេចក្តីដោយចៅក្រម ដែលត្រូវបានឆ្លងកាត់ច្រើនដំណាក់កាលនៅក្នុងការពិនិត្យមើលទៅលើស្ថានភាពជាក់ស្តែងរបស់ភាគីទាំងសងខាង ទើបចៅក្រមអាចធ្វើការសម្រេចសេចក្តី ដោយកំណត់នូវអ្នកដែលមានករណីយកិច្ចផ្តត់ផ្គង់ និងកម្មវត្ថុនៃអាហារកាតព្វកិច្ច ដោយដីកាសម្រេចបង្គាប់ឲ្យផ្តល់អាហារកាតព្វកិច្ចយ៉ាងជាក់លាក់។

# អនុសាសន៍

ក្រោយពីយើងខ្ញុំទាំងពីរ បានធ្វើការសិក្សាស្រាវជ្រាវលើ ប្រធានបទនេះមក យើងខ្ញុំយល់ឃើញថា អាហារកាតព្វកិច្ចតាមផ្លូវតុលាការ គឺជាការជួយសង្គ្រោះ និងធានាដល់បុគ្គលដែលមានជីវភាពខ្វះខាតផ្នែកហិរញ្ញវត្ថុនៅក្នុងការរស់នៅ ឲ្យអាចមានជីវភាពរស់នៅសមស្របមួយនៅក្នុងសង្គម។ ជាការយល់ឃើញរបស់ក្រុមយើងខ្ញុំផ្ទាល់ បើទោះបីជាក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាងបណ្តឹង បានប្បញ្ញត្តិអំពីការទាមទារអាហារកាតព្វកិច្ច ដើម្បីជាការផ្តល់នូវសិទ្ធិដល់បុគ្គលដែលដឹងថាខ្លួនកំពុងតែជួបប្រទះទៅ នឹងការលំបាកក្នុងការប្រកបរបរចិញ្ចឹមជីវិត ហើយជាជនដែលអាចទាមទារអាហារកាតព្វកិច្ចក៏ពិតមែន ប៉ុន្តែការចែងនេះហាក់បីនៅមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ។ អាស្រ័យហេតុដូច្នេះហើយ យើងខ្ញុំសូមផ្តល់ជាអនុសាសន៍ជូនដល់ ស្ថាប័នរដ្ឋ ស្ថាប័នតុលាការ និងស្ថាប័នដែលពាក់ព័ន្ធ ដូចខាងក្រោម៖

- គួរប្បញ្ញត្តិ អំពីប្រព័ន្ធនៃការវាយតម្លៃទៅលើជីវភាព របស់បុគ្គលដែលមានសិទ្ធិទាមទារអាហារកាតព្វកិច្ចឲ្យបានជាក់លាក់នៅក្នុងច្បាប់
- គួរកំណត់ឲ្យបានលំអិតចំពោះការគណនាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច ដោយការកំណត់នូវរូបមន្តឲ្យបានជាក់លាក់ ដើម្បីផ្តល់ជាភាពងាយស្រួលដល់ការវិនិច្ឆ័យសម្រេចសេចក្តីរបស់ចៅក្រម
- គួរប្បញ្ញត្តិអំពីវិធីសម្រេចសេចក្តីក្នុងការទាមទារអាហារកាតព្វកិច្ចឲ្យបានច្បាស់លាស់ ដើម្បីផ្តល់ជាភាពងាយស្រួល និងជួយសម្រួលដល់ការសម្រេចសេចក្តីឲ្យមានភាពឆាប់រហ័ស ជៀសវាងការសម្រេចសេចក្តីយឺតយ៉ាវរបស់ចៅក្រម
- គួរបង្កើនការផ្សព្វផ្សាយ អំពីអាហារកាតព្វកិច្ច និង នីតិវិធីនៃការទាមទារអាហារកាតព្វកិច្ចឲ្យបានទូលំទូលាយ ដើម្បីឲ្យប្រជាពលរដ្ឋបានយល់ដឹងពីសារៈសំខាន់របស់អាហារកាតព្វកិច្ចឲ្យកាន់តែប្រសើរឡើង ពីព្រោះនាពេលបច្ចុប្បន្នការយល់ដឹងរបស់ប្រជាពលរដ្ឋ ចំពោះការទាមទារអាហារកាតព្វកិច្ច នៅមានកម្រិតនៅឡើយទេ
- គួរពន្លឿនដំណើរការនៃការសម្រេចសេចក្តីឲ្យបានឆាប់រហ័ស និងទាន់ពេលវេលា ដើម្បីឲ្យជីវភាពរបស់ជនដែលមានសិទ្ធិទាមទារ រួចផុតពីស្ថានភាពលំបាក។ ពីព្រោះប្រសិនបើមិនមានចំណាត់ការនៅក្នុងការជួយពន្លឿនដំណើរការនៃសម្រេចសេចក្តីនោះទេ កត្តាជីវភាពរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច កាន់តែជួបការលំបាកខ្លាំងឡើង។

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១/, ៦ កក្កដា ២០០៦
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០/, ៨ ធ្នូ ២០០៧
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២/, ៣០ វិច្ឆិកា ២០០៩
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ព្រមទាំង សេចក្តីកំណត់ចំពោះមាត្រានីមួយៗ, លេខ នស/រកម/០៧១០/០១៣/, ១០ កក្កដា ២០១០
- ប្រកាសស្តីពីការកែសម្រួល ឧបសម្ព័ន្ធ១ និង ឧបសម្ព័ន្ធ៤ នៃប្រកាសលេខ ២៨ កយ ប្រក,០៧ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពី ប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធ ចំនួនទឹកប្រាក់ នៃពន្ធ ដាក់ពាក្យសុំ និង ចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឲ្យតុលាការសម្រេចសេចក្តី និង មាត្រដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្តី តុលាការក្រៅពីពន្ធ និង តម្លៃកម្មវត្ថុនៃបណ្តឹង

## ២. សៀវភៅ និងអត្ថបទផ្សេងៗ

- សេចក្តីកំណត់ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០
- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១៧
- សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
- លោកមេធាវី អ៊ុំ ប៉ូលី, ខែតុលា-ធ្នូ ឆ្នាំ២០១៧, ព្រឹត្តិបត្រមេធាវីលេខ ១៥ ស្តីពី អាហារកាតព្វកិច្ច។

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ | ឧបសម្ព័ន្ធ |
|---|---|---|
| ១ | តារាងថ្នាក់ញាតិ | ឧបសម្ព័ន្ធទី១ |
| ២ | មូលដ្ឋានគណនាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច | ឧបសម្ព័ន្ធទី២ |
| ៣ | ពាក្យសុំដីកាសម្រេចបង្គាប់ឲ្យផ្តល់អាហារកាតព្វកិច្ច | ឧបសម្ព័ន្ធទី៣ |
| ៤ | ដីកាសម្រេចបង្គាប់ឲ្យផ្តល់អាហារកាតព្វកិច្ច | ឧបសម្ព័ន្ធទី៤ |

# ឧបសម្ព័ន្ធទី១




តារាងស្ដីពីញាតិ និង ថ្នាក់ញាតិដែលរាប់ចេញពីសាមីខ្លួន

# ឧបសម្ព័ន្ធទី២

នេះជាមូលដ្ឋានគណនាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ចៈ

ចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច = សោហ៊ុយសម្រាប់ជីវភាពអប្បបរមារបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ឬ កម្មវត្ថុនៃអាហារកាតព្វកិច្ច

សោហ៊ុយសម្រាប់ជីវភាពអប្បបរមារបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច = ថ្លៃចំណាយរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច - ប្រាក់ចំណូលរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច

កម្មវត្ថុនៃអាហារកាតព្វកិច្ច = ចំណូលសរុបរបស់ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច - សោហ៊ុយក្នុងការចំណាយរបស់ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចលើការរស់នៅ

# ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំដីកាសម្រេចបង្គាប់ឲ្យផ្ដល់អាហារការតព្វកិច្ច**

**អ្នកដាក់ពាក្យសុំ** ៖ ឈ្មោះ X ភេទស្រី អាយុ ៥០ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ (គ្មាន) ផ្លូវលំ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៤ រាជធានីភ្នំពេញ។

**ភាគីម្ខាងទៀតនៃពាក្យសុំ** ៖ ឈ្មោះ Y ភេទប្រុស អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សំណើសុំតុលាការចេញដីកាសម្រេចដែលមានខ្លឹមសារថា ៖

(១) បង្គាប់ឲ្យឈ្មោះ Y បង់ប្រាក់ចំនួន **US$ ២០០ (ពីររយ) ដុល្លារអាមេរិក** ក្នុងមួយខែ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤

(២) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ Y

**យោង** ៖-មាត្រា **១១៤០** ដល់មាត្រា **១១៤៣** នៃក្រមរដ្ឋប្បវេណី

-មាត្រា **០៣** និងមាត្រា **២៦** នៃច្បាប់នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

សេចក្ដីដូចមានកំណត់ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖

..........................................................................................................................

..........................................................................................................................

..........................................................................................................................

**ក-អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

-

**ខ.ឥស្សុតាខជាឯកសារ**

-

-

-

សេចក្តីដូចជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាសម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**ស្នាមម្រាមដៃ**

# ឧបសម្ព័ន្ធទី៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ០១ ចុះថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤

-ដីកាសម្រេចលេខ ០១ "ក" ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤

**<u>ដីកាសម្រេចបង្គាប់ឲ្យផ្តល់អាហារកាតព្វកិច្ច</u>**

យើង W ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា ០៣ និងមាត្រា ២៦ នៃច្បាប់នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

-បានឃើញមាត្រា ១១៤០ ដល់មាត្រា ១១៤៣ នៃក្រមរដ្ឋប្បវេណី

-បានឃើញសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ០១ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ

រវាងអ្នកដាក់ពាក្យសុំឈ្មោះ X អាយុ ៥០ ឆ្នាំ ភេទស្រី សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ (គ្មាន) ផ្លូវលំ ក្រុម១ ភូមិ២ សង្កាត់៣ ខណ្ឌ៤ រាជធានីភ្នំពេញ។

និងភាគីម្ខាងទៀតនៃពាក្យសុំឈ្មោះ Y អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

ខ្លឹមសារនៃដីកាសម្រេចដែលត្រូវបានស្នើសុំដោយអ្នកដាក់ពាក្យសុំ (X)៖

-បង្គាប់ឲ្យឈ្មោះ Y បង់ប្រាក់ចំនួន US$ ២០០ (ពីររយ) ដុល្លារអាមេរិក ក្នុងមួយខែ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ Y

**ក.ដំណើររឿង**

ក-១ ការអះអាងរបស់ X ៖

ក-២ ការអះអាងរបស់ Y ៖

**ខ.ភស្តុតាងក្នុងសំណុំរឿង**

ខ-១ ភស្តុតាងរបស់ X ៖

ខ-២ ភស្តុតាងរបស់  Y ៖

**នាពេលសាកសួរភាគីនៃសំណុំរឿង**

-

-

**សំអាងហេតុ**

-

## ហេតុដូច្នេះទិនិច្ឆ័យសេចក្តី

១-បង្គាប់ឲ្យឈ្មោះ  Y បង់ប្រាក់ចំនួន **US$ ២០០ (ពីររយ) ដុល្លារអាមេរិក** ក្នុងមួយខែ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៥ ទៅឲ្យឈ្មោះ X

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ Y

ដីកាសម្រេចនេះទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី  ១៦  ខែ  ធ្នូ  ឆ្នាំ ២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ នៅចំពោះមុខអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតនៃពាក្យសុំ។

ទុកសិទ្ធិឲ្យប្តឹងជំទាស់ក្នុងអំឡុងពេល  ០២ ( ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីដីកាសម្រេចនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤

**ចៅក្រម**